**Establishment and Operation of a Regional System of Fisheries *Refugia* in the South China Sea and Gulf of Thailand**

# REPORT

# REVIEWING 3 YEARS MANAGEMENT PLAN FOR MARINE FISHERIES MANAGEMENT AREA

**KEP, CAMBODIA**

07-08 FEBRUARY 2019

Prepared by

**FISHERIES ADMINISTRATION, CAMBODIA**

SOUTHEAST ASIAN FISHERIES DEVELOPMENT CENTER
TRAINING DEPARTMENT

**Southeast Asian Fisheries Development Center** | **United Nations Environment** | **Global Environment Facility**

First published in Phrasamutchedi, Samut Prakan, Thailand in February 2019 by the SEAFDEC-UNEP-GEF Fisheries Refugia Project, Training Department of the Southeast Asian Fisheries Development Center

Copyright © 2019, SEAFDEC-UNEP-GEF Fisheries *Refugia* Project

This publication may be reproduced in whole or in part and in any form for educational or non-profit purposes without special permission from the copyright holder provided acknowledgement of the source is made. The SEAFDEC-UNEP-GEF Fisheries *Refugia* Project would appreciate receiving a copy of any publication that uses this publication as a source.

No use of this publication may be made for resale or for any other commercial purpose without prior permission in writing from the SEAFDEC Secretary-General at.

Southeast Asian Fisheries Development Center
Training Department
P.O.Box 97, Phrasamutchedi, Samut Prakan, Thailand
Tel: (66) 2 425 6100
Fax: (66) 2 425 6110
https://fisheries-refugia.org and
https://seafdec.or.th

**DISCLAIMER:**

The contents of this report do not necessarily reflect the views and policies of the Southeast Asian Fisheries Development Center, the United Nations Environment Programme, and the Global Environment Facility.

For citation purposes this document may be cited as:

FIA/Cambodia, 2019. Establishment and Operation of a Regional System of Fisheries Refugia in the South China Sea and Gulf of Thailand, Report of Reviewing 3 Years Management Plan for Marine Fisheries Management Area. Southeast Asian Fisheries Development Center, Training Department, Samut Prakan, Thailand; Fisheries Refugia Rep-CAM25, 62 p.

**1. Open meeting**

**1)** Mr. Ouk Vibol, Director of Department of Fisheries Conservation, expressed thanks to Mr. Prom Kunti, deputy governor of Kep and director of Kep FiAC and offices from kep administration taking their opportunity to join that meeting. This is a good chance to meet and discuss together on draft 3 year management plan preparation for MFMA in Kep (see annex 1 and 2).

**2)** Mr. Prom Kunti, Deputy Governor of Kep welcomed to all participants, especially Mr. Ouk Vibol, and informed that the management plan is corrected from technical working group again but, it is still not good for what we wanted, so we need more inputs or ideas or comments from meeting to ensure that the plan is better.

**2. Presentation of draft 3 year management plan for MFMA in Kep**

3) Mr. Ouk Vibol presented draft 3 year management plan for MFMA in Kep to meeting. He informed that he reduced from 5year-plans to 3 year-plan because there are spending a lot of money and hard to find budget to implement it when the project finished (see annex 4).

4) He added that he cut down from 9 objectives of the plan to 6 objectives because some objectives are the similar, so he combined into one objective. The estimated budget is around USD 618,720, but there are no budgets to implement yet. So we need to seek money together. Department of Fisheries Conservation has budgets from EU for deploying concrete box and from SEAFDEC/UNEP/GEF for meeting preparation, extension, and patrolling.

5) Based on the proclamation of MFMA in Kep, FiA and Kep Administration need to work together in order to ensure the effective implementation of MFMA in Kep

6) He suggested meeting to review and correct each paragraph.

**3. Discussion draft 3 year management plan for MFMA in Kep**

7) Mr. Prom Kunti suggested meeting to check spelling, meaning by each paragraph and proposed Mr. Kuch Virak, Director of Kep FiAC to help check, and correct the figure, fish production as mentioned in Introduction.

8) The meeting agreed the draft 3 year-management plan for MFMA in kep, but the draft plan need to meet and discuss with 2nd Technical Working Group any day this month before it will be submitted and approved by the Governor of Kep and Director General of Fisheries Administration.

9) Mr. Prom Kunti suggested meeting to follow up the VN's activities that always entries Cambodia's territory, if they are coming for fishing or tourism.

**4. Close meeting**

10) Mr. Ouk Vibol thanked very much to Deputy Governor and Director of Kep FiAC and other officers again, providing inputs and ideas to make the plan better. The plan is also used to seek budget from other source and he suggested Mr. Kuch Virak to find budget from EU for patrolling as well.

11) He suggested the teamwork from the province to monitor and speed up that job and then it is submitted to 2nd Technical Working Group meeting.

12) He added that DFC is ready to have some budgets to exchange study tour at countries such as Viet Nam and Thailand. The meeting closed at 5:30pm

## ANNEX 1

### List of participants attending reviewing 3 years management plan for marine fisheries management area in Kep on 7 to 8 February 2019

| Name | Sex | Title | Organization | Telephone |
|---|---|---|---|---|
| 1. Prom Kunti | M | Deputy Governor of Kep | Kep Administration | 012974816 |
| 2. Ouk Vibol | M | Director | DFC/FiA | 012908121 |
| 3. Kuch Virak | M | Director | Kep FiAC | 012875587 |
| 4. Kyng Sophanny | M | Vice chief | Kep FiAC | 012494269 |
| 5. Chhork Sineath | M | Chief of Fisheries Administration Division | Kep FiAC | 012828926 |
| 6. Chhun Chanvanthun | M | Director of Administration Division | Kep Administration | 017861444 |
| 7. Kao Monirith | M | Deputy Director | Marine Fisheries Administration Inspectorate | 012583828 |
| 8. Leng Sy Vann | M | Deputy Director | DFC/FiA | 017446373 |

## ANNEX 2

### Schedule for reviewing 3 years management plan for marine fisheries management area in Kep on 7 to 8 February 2019

| Date/Time | Description | Responsible person |
|---|---|---|
| **06 February 2019** | | |
| 10:00am-2:30pm | Leaving Phnom Penh for Kep | • Mr. Ouk Vibol<br>• Mr. Leng Sy Vann<br>• Mr. Kao Monirith<br>• Ms. Va Sotepy |
| **07 February 2019** | | |
| 8:30am- 9:00am | Registration | All |
| 9:00am- 10:00pm | Presentation of draft 3 year management plan for MFMA in Kep | Mr. Ouk Vibol Director of Department of Fisheries Conservation |
| 10:00pm-12:00pm | Discussion and review draft 3 year management plan for MFMA in Kep | Mr. Prom Kunti Deputy Governor of Kep |
| 12:00pm-2:00pm | Lunch break | |
| 2:00pm-5:00pm | Discussion and review draft 3 year management plan for MFMA in Kep | Mr. Prom Kunti Deputy Governor of Kep |

| | | |
|---|---|---|
| **08 February 2019** | | |
| 9:00am-12:00pm | Discussion and review draft 3 year management plan for MFMA in Kep | Mr. Prom Kunti Deputy Governor of Kep |
| 12:00pm -2:00pm | Lunch | |
| 2:00pm-5:00pm | Discussion and review draft 3 year management plan for MFMA in Kep | Mr. Prom Kunti Deputy Governor of Kep |
| **09 February 2019** | | |
| 9:00am -4:00pm | Leaving Koh Kong for Phnom Penh | All |

**ANNEX 3**

**Participants' Photos attending reviewing 3 year management plan for marine fisheries management area in Kep on 7 to 8 February 2019**









ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងតំបន់គ្រប់គ្រងជលផល សមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប រយៈពេល៥ឆ្នាំ ២០១៩-២០២១

# 5-YEAR MANAGEMENT PLAN FOR MARINE FISHERIES MANAGEMENT AREA IN KOH PO AND KOH TONSAY ARCHIPELAGO, KEP PROVINCE (2019-2021)



**មីនា ២០១៩**

# មាតិការ


មាតិការ ........................................................ ii

បញ្ជីតារាង ........................................................ iv

បញ្ជីរូបភាព ........................................................ iv

អក្សរកាត់ ........................................................ viii

**១. សេចក្ដីផ្ដើម** ........................................................ 1

១.១ លក្ខណៈភូមិសាស្រ្ត និងគុណតម្លៃប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ ........................................................ 1

១.២ ប្រភេទជម្រកជលផលនិងជីវចម្រុះ ........................................................ 2

១.៣ តំបន់ឆ្នេរខេត្តកែប ........................................................ 5

១.៣.១ ប្រជាសាស្រ្ត ........................................................ 6

១.៣.២ ធនធានសមុទ្រនៃខេត្តកែប ........................................................ 7

១.៣.៣ប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ឆ្នេរខេត្តកែប (ប្រជុំកោះពោធិ៍និងកោះទន្សាយ) ........................................................ 9

១.៣.៤ ការគំរាមកំហែង (Threats) ........................................................ 11

១.៣.៥ កិច្ចការពារនាបច្ចុប្បន្ន ........................................................ 12

**២. តំបន់គ្រប់គ្រងជលផលសមុទ្រ** ........................................................ 12

២.១ គោលបំណងនៃការបង្កើតMFMA ........................................................ 14

២.២ ការកំណត់តំបន់គ្រប់គ្រង ........................................................ 14

២.២.១ -កន្លែងអភិរក្សជលផល ........................................................ 14

២.២.២-កន្លែងការពារធនធានជលផល ........................................................ 15

២.២.៣-ដែនជម្រកសុវត្ថិភាពជលផល ........................................................ 15

២.២.៤-កន្លែងអេកូទេសចរណ៍បាតសមុទ្រ ........................................................ 15

**៣. ក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ** ........................................................ 15

**៤. ផែនការសកម្មភាព** ........................................................ 16

៤.១ គោលដៅ ........................................................ 16

៤.២ គោលបំណង ........................................................ 17

៤.៣ សកម្មភាពមេដែលសម្រេចគោលបំណង ........................................................ 17

**៥. រចនាសម្ព័ន្ធសម្រាប់ការអនុវត្តសកម្មភាពនិងការទទួលខុសត្រូវ** ........................................................ 19

**៦. ថវិកាប៉ាន់ស្មាន** ........ 19

**៧. ការតាមដាន និងវាយតម្លៃ** ........ 20

**៨. ឧបសម្ព័ន្ធ** ........ 22

ឧបសម្ព័ន្ធ ១៖ តារាងសកម្មភាពលំអិត សូចនាករ ពេលវេលា ស្ថាប័នអនុវត្ត និងថវិកា ........ 22

ឧបសម្ព័ន្ធ ២៖ ប្រកាសស្តីពីការបង្កើតតំបន់គ្រប់គ្រងជលផលនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប 36

ឧបសម្ព័ន្ធ៣៖ សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងនិងក្រុមការងារបច្ចេកទេសតំបន់គ្រប់គ្រងជលផល ខេត្តកែប ........ 44

## បញ្ជីតារាង

តារាងទី១៖ ប្រភេទផលសមុទ្រសំខាន់ៗដែលចាប់បានជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ២០១២ ដល់២០១៧ (ឯកត្តាគិតជាតោន)......3

តារាងទី២៖ ប្រភេទធនធានជលផលសមុទ្រដែលរងគ្រោះថ្នាក់នៅក្នុងប្រទេសកម្ពុជា......4

តារាងទី៣៖ ប្រភេទធនធានជលផលសំខាន់ដែលប្រមូលបានក្នុងតំបន់ឆ្នេរខេត្តកែប......7

តារាងទី៤៖ ផលចាប់សរុបប្រចាំឆ្នាំតាមខេត្ត (គិតជាតោន)......8

តារាងទី៥៖ សូចនាករនៃអនុកម្មវិធីទី១ នៃវិស័យជលផល......16

## បញ្ជីរូបភាព

FIGURE 1៖ ផែនទីជម្រកជលផលក្នុងតំបន់ឆ្នេរនៃប្រទេសកម្ពុជា......2

FIGURE 2៖ ផលចាប់សរុបធនធានជលផលសមុទ្រប្រចាំឆ្នាំ......3

FIGURE 3៖ ផែនទីខេត្តកែប......5

FIGURE 4៖ របាយប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ឆ្នេរខេត្តកែប......11

FIGURE 5៖ ផែនទីតំបន់គ្រប់គ្រងជលផលក្នុងប្រជុំកោះពោធិ៍និងកោះទន្សាយខេត្តកែប......14

# អារម្ភកថា

## ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

ព្រះរាជាណាចក្រកម្ពុជាគឺជាប្រទេសមួយប្រកបដោយធនធានធម្មជាតិយ៉ាងសំបូរបែប ជាពិសេសធនធានជលផលសមុទ្ររួមមានផ្កាថ្ម ស្មៅសមុទ្រ និងព្រៃកោងកាងដែលមានសារៈសំខាន់បំផុតសម្រាប់មនុស្សជាតិនិងលំនឹងធម្មជាតិ។ ប្រព័ន្ធអេកូឡូស៊ីទាំងនេះគឺជាមូលដ្ឋានគ្រឹះផ្តល់ផលប្រយោជន៍យ៉ាងសំខាន់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជារាប់លាននាក់ និងដល់ប្រទេសជាតិទាំងមូល។ ធនធានទាំងនេះ មិនត្រឹមតែដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ត្រីជាអាហារប្រចាំថ្ងៃដល់ប្រជាពលរដ្ឋកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយការពារឆ្នេរសមុទ្រ និងផ្តល់សេវាទេសចរណ៍ទៀតផង។

តាមការស្រាវជ្រាវរបស់រដ្ឋបាលជលផលនិងដៃគូអភិរក្សផ្សេងៗ បានបង្ហាញឱ្យឃើញថា ប្រព័ន្ធអេកូឡូស៊ីទាំងនេះមានច្រើននៅក្នុងតំបន់ប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប ជាពិសេសស្មៅសមុទ្រ និងផ្កាថ្ម ដែលអាចទាក់ទាញអ្នកទេសចរណ៍រាប់ម៉ឺននាក់មកកំសាន្តក្នុងមួយឆ្នាំៗ។ ទោះជាយ៉ាងនេះក្តី ប្រព័ន្ធអេកូឡូស៊ីទាំងនេះបាននឹងកំពុងទទួលរងនូវការគំរាមកំហែងជាពិសេសការនេសាទខុសច្បាប់ដោយអួនអូសក្នុងតំបន់ទឹករាក់ ការបង្ហូរកាកសំណល់ផ្សេងៗទៅក្នុងសមុទ្រ ការបោះចោលសំណល់ឧបករណ៍នេសាទ ការលួចកាច់ផ្កាថ្មលក់ ការជាក់បំបាក់ផ្កាថ្មពីទេសចរមុជទឹក និងការទម្លាក់យុថ្កាលើតំបន់ផ្កាថ្មនិងស្មៅសមុទ្រ។

ដើម្បីឱ្យការគ្រប់គ្រងតំបន់នេះកាន់តែមានប្រសិទ្ធភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុម័តប្រកាសលេខ១៩៣ ប្រក.កសក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ស្តីពីការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងប្រជុំកោះទន្សាយ ខេត្តកែប ដោយមានការគាំទ្រពីរដ្ឋបាលខេត្តកែប។ ជាមួយគ្នានោះផងដែរ ក្រុមការងារជំនាញរបស់រដ្ឋបាលជលផល រដ្ឋបាលខេត្តកែប មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកែប សហគមន៍នេសាទ អង្គការអភិរក្សជលផលកម្ពុជា អង្គការIUCN និងអ្នកពាក់ព័ន្ធផ្សេងៗទៀតបានរៀបចំផែនការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្ររយៈពេលប្រាំពីឆ្នាំ២០១៩-២០២១ ដើម្បីឱ្យការគ្រប់គ្រងតំបន់នេះមានប្រសិទ្ធភាពនិងការទទួលខុសត្រូវខ្ពស់។ ការរៀបចំផែនការនេះ ក៏ជាផ្នែកមួយជួយឱ្យសម្រេចគោលដៅផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្មផងដែរ។

ក្នុងនាមរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមគាំទ្រយ៉ាងពេញទំហឹងនូវការរៀបចំផែនការគ្រប់គ្រងនេះ និងដាក់ឲ្យដំណើរការជាផ្លូវការ ដើម្បីសម្រេចនូវគោលបំណងទាំងប្រាំ គឺធានាឱ្យបាននូវនិរន្តរភាពការនេសាទជាលក្ខណៈគ្រួសារ ការអភិរក្សធនធានជីវចម្រុះជលផល និងចូលរួមចំណែកលើកស្ទួយទេសចរណ៍ធម្មជាតិ ដើម្បីបង្កើនកំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋយើង។

ថ្ងៃ រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

## អារម្ភកថា
## ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកែប

កែបជាខេត្តមួយ ដែលមានសក្តានុពលខ្ពស់លើវិស័យទេសចរណ៍ ដែលជាចំណូលដ៏សំខាន់បំផុតសម្រាប់លើកស្ទួយវិស័យសេដ្ឋកិច្ចនិងការអភិវឌ្ឍ។ ប្រជាពលរដ្ឋក្នុងខេត្តកែបមានមុខរបរពឹងផ្អែកលើធនធានធម្មជាតិ ដូចជាវិស័យទេសចរណ៍ធម្មជាតិ ការនេសាទ ការធ្វើស្រែអំបិល និងការធ្វើស្រែចំការ។

កែបជាទីក្រុងស្អាត បានទទួលពានរង្វាន់ផ្ការំដួល០៣ទង ចំនួន០២លើកជាប់គ្នាក្នុងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត"។ រាជរដ្ឋាភិបាលបានកំណត់ចក្ខុវិស័យខេត្តកែប ជាខេត្តទេសចរណ៍សម្រាកលំហែកំសាន្តប្រណិតកំរិតខ្ពស់ហើយក៏មិនបានអនុញ្ញាតឱ្យមានជារោងចក្រឧស្សាហកម្មធំៗឡើយ។ កន្លងមក ខេត្តកែបក៏បានទទួលនូវពានរង្វាន់ "ទីក្រុងនិរន្តរភាពបរិស្ថានអាស៊ាន" លើសូចនាករ ដីស្អាតទឹកស្អាត និងខ្យល់ស្អាត ដែលប្រគល់នៅប្រទេសប្រ៊ុយណេនាឆ្នាំ២០១៧និងទទួលបានពានរង្វាន់"ទីក្រុងទេសចរណ៍ស្អាតអាស៊ាន" ដែលប្រគល់នៅខេត្តឈៀងម៉ៃនៃព្រះរាជាណាចក្រថៃនាឆ្នាំ២០១៨។ បច្ចុប្បន្ន ខេត្តកែបជា "ទីក្រុងអាស៊ានឈានមុខឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ដោយចីរភាព" ព្រមជាមួយនោះ ខេត្តក៏កំពុងឈរជាបេក្ខភាពមួយទៀតក្នុងការប្រឡងប្រណាំងយកពានរង្វាន់ "ទីក្រុងជីវចម្រុះអាស៊ានចិន" ។ ភាពជោគជ័យជាបន្តបន្ទាប់នេះ ដោយសារខេត្តកែប មានយុទ្ធសាស្ត្រអភិវឌ្ឍន៍ច្បាស់លាស់ជាពិសេស យុទ្ធសាស្ត្រគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន។

ក្នុងនាមគណៈអភិបាលនិងប្រជាពលរដ្ឋទូទាំងខេត្ត ខ្ញុំសូមថ្លែងអំណរគុណនិងគាំទ្រ ដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏ដូចជារដ្ឋបាលជលផលនិងក្រុមការងារទាំងអស់ ដែលបានយកចិត្តទុកដាក់ក្នុងការការពារធនធានទាំងនេះ តាមរយៈការបង្កើតឱ្យមានតំបន់គ្រប់គ្រងជលផលសមុទ្រមួយកន្លែង ដែលធ្វើឱ្យអាជ្ញាធរខេត្តយើងខ្ញុំមានលិខិតបទដ្ឋានគតិយុត្តត្រឹមត្រូវក្នុងការចូលរួមគ្រប់គ្រងធនធានធម្មជាតិ ព្រមទាំងជួយសម្រេចបាននូវយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខេត្តផងដែរ។

ចំពោះមុខនេះ រដ្ឋបាលខេត្តកែប សូមកោតសរសើរដោយស្មោះ ចំពោះក្រុមការងារបច្ចេកទេសជំនាញមកពីរដ្ឋបាលជលផល រដ្ឋបាលខេត្តកែប ខណ្ឌរដ្ឋបាលជលផលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត អង្គការ SEAFDEC/UNEP/GEF អង្គការអភិរក្សសមុទ្រកម្ពុជា(MCC) អង្គការIUCN/MFF និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដែលបានរៀបចំផែនការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយរយៈពេល៣ឆ្នាំ ពី២០១៩-២០២១នេះឡើង ដែលជាឯកសារដ៏សំខាន់បំផុតសម្រាប់ការអនុវត្តសកម្មភាពឱ្យចំទិសដៅ និងសម្រេចគោលបំណងដែលបានគ្រោងទុក។

ជាថ្មីម្តងទៀត ក្នុងនាមរដ្ឋបាលខេត្តកែប ខ្ញុំសូមគាំទ្រនូវឯកសារផែនការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រនេះ ហើយរដ្ឋបាលខេត្តនឹងចូលរួមសហការអនុវត្តផែនការគ្រប់គ្រងនេះ ដើម្បីធានាបាននូវភាពគង់វង្សធនធានធម្មជាតិសម្រាប់បម្រើឱ្យប្រជាពលរដ្ឋនិងកូនចៅយើងជំនាន់ក្រោយៗទៀត។

ថ្ងៃ ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២

ខេត្តកែប ថ្ងៃទី ខែ ឆ្នាំ២០១៩

**អភិបាលនៃគណៈអភិបាលខេត្តកែប**

# សេចក្តីថ្លែងអំណរគុណ

## ក្រុមអ្នករៀបចំនិងកែសម្រួល

លោក អ៊ុក វិបុល លោក ព្រុំ គន្ធិ លោក ឡេង ស៊ីវណ្ណ លោក គឹម សុខា លោក គុជ វិរៈ លោក Tom Collombat និងកញ្ញា ថាប់ រចនា

## អ្នកផ្តល់ព័ត៌មានបន្ថែម

លោក ចឹង បូរិន លោកយូ ចន្ទប្រសិទ្ធ លោកPaul Ferber លោក គីង សុផានី លោក ឈុន ច័ន្ទវ៉ាន់ថុន លោកចក់ ស៊ីនាថ សមាជិកនៃគណៈកម្មការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែបនិងក្រុមការងារបច្ចេកទេសសម្រាប់តំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប។

## សេចក្តីថ្លែងអំណរគុណ

ក្នុងនាមអ្នករៀបចំផែនសកម្មភាពសម្រាប់ការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំនិងក្រុមការងារបច្ចេកទេសនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលជលផល និងរដ្ឋបាលខេត្តកែប ដែលបានបង្កលក្ខណៈងាយស្រួល និងជួយផ្តល់អនុសាសន៍ល្អៗក្នុងការរៀបចំតំបន់គ្រប់គ្រងជលផលសមុទ្រក្នុងខេត្តកែបនេះឡើង ព្រមទាំងជួយកែសម្រួលនិងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ដើម្បីធានាការអនុវត្តសកម្មភាពប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវខ្ពស់។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ SEADEC/UNEP/GEF អង្គការអភិរក្សសមុទ្រកម្ពុជា (MCC) និងអង្គការ IUCN/MFF ដែលជួយគាំទ្រថវិកានិងបច្ចេកទេស ក្នុងការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រក្នុងខេត្តកែប និងផែនការគ្រប់គ្រងរយៈពេល៣ឆ្នាំនេះឡើង។

## អង្គការដៃគូ

# អក្សរកាត់

| | |
|---|---|
| MCC (Marine Conservation Cambodia) | អង្គការអភិរក្សសមុទ្រកម្ពុជា |
| DFC (Department of Fisheries Conservation) | នាយកដ្ឋានអភិរក្សជលផល |
| FiA (Fisheries Administration) | រដ្ឋបាលជលផលខណ្ឌរដ្ឋបាលជលផលកែប |
| TWG-MFMA-Kep (Technical Working Group for Kep MFMA) | ក្រុមការងារបច្ចេកទេសសម្រាប់តំបន់គ្រប់គ្រងជលផលខេត្តកែប |
| PMB-MFMA-Kep (Provincial Management Board for Kep MFMA) | ក្រុមប្រឹក្សាគ្រប់គ្រងតំបន់គ្រប់គ្រងជលផលខេត្តកែប |
| MFMA (Marine Fisheries Management Area) | តំបន់គ្រប់គ្រងជលផលសមុទ្រ |
| FAO (Food and Agriculture Organisation) | អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ |
| IUCN (International Union for Conservation of Nature) | សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ |
| MFF (Mangroves for the Future) | ព្រៃកោងកាងដើម្បីអនាគត |
| SEAFDEC (South East Asia Fisheries Development Center) | មជ្ឈមណ្ឌលអភិវឌ្ឍជលផលនៃអាស៊ាន |
| GEF (Global Environment Facility) | មូលនិធិបរិស្ថានសាកល |
| UNEP (United Nation Environment Program) | កម្មវិធីបរិស្ថានសហប្រជាជាតិ |

## ១. សេចក្តីផ្តើម

### ១.១ លក្ខណៈភូមិសាស្ត្រ និងគុណតម្លៃប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ

ព្រះរាជាណាចក្រកម្ពុជាស្ថិតនៅភាគខាងត្បូងនៃឧបទ្វីបឥណ្ឌូចិននៃតំបន់អាស៊ីអាគ្នេយ៍។ ឆ្នេរសមុទ្រកម្ពុជាលាតសន្ធឹងប្រវែង៤៤០គីឡូម៉ែត្រតាមបណ្តោយឈូងសមុទ្រថៃ ដែលជាប់ព្រំដែនថៃនិងវៀតណាមហើយតំបន់សេដ្ឋកិច្ចផ្តាច់មុខមានទំហំ៥៥.៦០០គ.ម[២](Nelson, 1999)។

ប្រទេសកម្ពុជាមានតំបន់ឆ្នេរសមុទ្រចំនួន០៤ខេត្ត រួមមាន ខេត្តព្រះសីហនុ ខេត្តកំពត ខេត្តកោះកុង និងខេត្តកែប។ ដែនទឹកសមុទ្ររបស់ប្រទេសកម្ពុជាគ្របដណ្តប់កោះចំនួន៦៩កោះដែលមានជីវចម្រុះសមុទ្រខ្ពស់រួមមានថ្មប៉ប្រះទឹក(ផ្កាថ្ម) ប្រហាក់ប្រហែលប្រមាណ២.៨០៦ហិកតា ស្មៅសមុទ្រ៣០.០០០ហិកតា និងព្រៃកោងកាងប្រហែល៧៨.៤០០ហិកតាធ្វើឲ្យបរិស្ថានសមុទ្រក្នុងតំបន់នេះសំបូរដោយជីវៈចម្រុះ។

ធនធានជលផលជាពិសេសត្រីគឺជាអាហារដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជា ហើយដើរតួនាទីយ៉ាងសំខាន់សម្រាប់សន្តិសុខស្បៀង។ តាមការស្រាវជ្រាវរបស់រដ្ឋបាលជលផលក្នុងឆ្នាំ២០០៨ ត្រីបានផ្តល់ប្រូតេអ៊ីនជាង៨១,៥ភាគរយនៅក្នុងរបបអាហារប្រចាំថ្ងៃរបស់ប្រជាជនយើង។ ត្រីសម្បូរដោយប្រូតេអ៊ីនវីតាមីន និងសារធាតុខនិជផ្សេងៗទៀតដែលមានសារៈសំខាន់សម្រាប់សុខភាពមនុស្សជាពិសេសស្ត្រីមានផ្ទៃពោះនិងកុមារ។

ប្រជាជនខ្មែរយើងនិយមបរិភោគត្រីច្រើន បើប្រៀបធៀបទៅនឹងប្រជាជនដែលរស់នៅក្នុងបណ្តាប្រទេសនៃអាងទន្លេមេគង្គក៏ដូចជានៅលើសកលលោកទាំងមូលដែរ។ គិតជាមធ្យមប្រជាពលរដ្ឋម្នាក់ៗ បរិភោគត្រីប្រមាណ៥២,៤គ.ក្រក្នុងមួយឆ្នាំ។

ធនធានជលផលបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងសង្គមនិងសេដ្ឋកិច្ចជាតិ ដោយបានផ្តល់ជាមុខរបរដល់ប្រជាជនកម្ពុជាជាង៦លាននាក់ដែលមានការងារពាក់ព័ន្ធជាមួយនឹងមុខរបរនេសាទ។ វិស័យជលផលជាប្រភពផ្តល់ប្រាក់ចំណូលយ៉ាងសំខាន់សម្រាប់ទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរ ជាពិសេសអ្នករស់នៅតាមជនបទ។

ធនធានជលផល ក៏ជាប្រភពមួយយ៉ាងសំខាន់ក្នុងការទាក់ទាញការចាប់អារម្មណ៍របស់ភ្ញៀវទេសចរណ៍ជាតិនិងអន្តរជាតិផងដែរ ដូចជាការនេសាទត្រីកំសាន្ត ការទស្សនានៅភូមិអ្នកនេសាទបណ្តែតទឹកនៅចុងឃ្នាស ខេត្តសៀមរាប ការទស្សនាផ្សោតនៅព្រែកកាំពីខេត្តក្រចេះ ការទស្សនាតាមតំបន់ព្រៃលិចទឹក និងព្រៃកោងកាង និងការមុជទឹកមើលផ្កាថ្មជាដើម។ សកម្មភាពទាំងនេះ បានចូលរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិរបស់ប្រទេសកម្ពុជាយើងឱ្យបានរីកចំរើន។

ក្រៅពីនេះ ធនធានជលផលក៏ជាប្រភពមួយដែលធ្វើអោយប្រជាជនជាច្រើននៅលើសកលលោកបានស្គាល់ពីកម្ពុជាតាមរយៈសិលាចារឹកលើជញ្ជាំងប្រាសាទអង្គរវត្ត និងប្រាសាទបាយ័ន និងភាពសម្បូរបែបនៃត្រីទឹកសាប ដែលចាប់បានពីធម្មជាតិមានបរិមាណច្រើន។ ម្យ៉ាងទៀត ប្រទេសយើងមានត្រីមួយចំនួនដែលមានលក្ខណៈពិសេសដោយឡែកពីប្រទេសដ៏ទៃដូចជាត្រីរាជ និងត្រីគល់រាំង ជាប្រភេទត្រីទឹកសាបធំមួយនៅលើពិភពលោក ព្រមទាំងត្រីបបែលយក្ស និងផ្សោតទឹកសាបជាដើម។ ត្រីក៏ជាអត្តសញ្ញាណជាតិមួយដែរ ព្រោះថាប្រជាជនខ្មែរយើងមានទំនៀមទម្លាប់ វប្បធម៌ និងប្រពៃណីបរិភោគប្រហុកដែលមិនអាចខ្វះបានតាំងពីបុរាណកាលមក។

## ១.២ ប្រភេទជម្រកជលផលនិងជីវចម្រុះ

ផ្កាថ្មក្នុងប្រទេសកម្ពុជា ភាគច្រើនស្ថិតនៅក្បែរៗកោះ ក្នុងទីដែលមានទឹករាក់ៗ ចន្លោះជម្រៅទឹកពី២,៥-៣០ម (Krell et al. 2011)។ ទីជម្រកសំខាន់ៗទាំងនេះទ្រទ្រង់ជីវចម្រុះការនេសាទរបរចិញ្ចឹមជីវិតនិងផ្តល់កិច្ចការពារឆ្នេរសមុទ្រ តាមរយៈនិយ័តកម្មប្រព័ន្ធអាកាសធាតុពិភពលោកការកាត់បន្ថយបាតុភូតមិនប្រក្រតីនៃធម្មជាតិនិងប្រព្រឹត្តកម្មសំណល់ (Cesar, 2000; Brander et al., 2007; Londono & Johnston 2012)។ស្មៅសមុទ្រមាននាទីដ៏សំខាន់សម្រាប់ជាកន្លែងរកចំណីនៃសត្វសមុទ្រដូចជាអណ្តើកនិងត្រីឆ្លាម (Heithaus et al 2002; Taquet et al 2006; Bjorndal & Bolten 2010)។ លើសពីនេះព្រៃកោងកាងគឺជាទីជម្រកដ៏មានប្រយោជន៍សម្រាប់ការរកចំណីនិងការលូតលាស់នៃប្រភេទត្រីជាច្រើន (Blaber et al 1989; Lugendo et al 2005; Lugendo et al 2007) និងដើរតួជាប្រព័ន្ធការពារឆ្នេរសមុទ្រសម្រាប់សហគមន៍ជាច្រើនដែលរស់នៅតាមឆ្នេរសមុទ្រនៃប្រទេសកម្ពុជា (Kathiresan & Rajendran 2005)។ បរិស្ថានសមុទ្រនិងតំបន់ឆ្នេរនៃប្រទេសកម្ពុជាក៏មានតួនាទីកាន់តែសំខាន់ផងដែរនៅក្នុងការអភិវឌ្ឍប្រទេសទ្រទ្រង់កសិកម្មជលផល វិស័យឧស្សាហកម្មនឹងដឹកជញ្ជូននិងផ្តល់ភាពទាក់ទាញកាន់តែច្រើនសម្រាប់វិស័យទេសចរណ៍និងការលំហែកាយផងដែរ។ ការនេសាទសមុទ្រផ្តល់ជាផលចំណូលសម្រាប់ការចិញ្ចឹមជីវិតនិងជាមធ្យោបាយសម្រាប់ទ្រទ្រង់ការរស់នៅរបស់ប្រជាជនជាច្រើនគ្រួសារនៅកម្ពុជា ដោយមានបរិមាណផលនេសាទសមុទ្រសរុបប្រមាណ១២១.០២៥តោន (២០១៧) កើនប្រមាណជិត៣០% ប្រៀបនឹងផលចាប់ក្នុងឆ្នាំ២០១០។ការអភិរក្សទីជម្រកទាំងនេះគឺមានសារៈសំខាន់បំផុតដោយសារតែគុណតម្លៃជាច្រើនបែបនៃប្រព័ន្ធអេកូឡូស៊ីនិងសម្រាប់សេដ្ឋកិច្ចដែលជាប់ទាក់ទងនឹងទីជម្រកទាំងនេះ។




Figure 1៖ ផែនទីជម្រកជលផលក្នុងតំបន់ឆ្នេរនៃប្រទេសកម្ពុជា

ធនធានជលផលគឺជាមូលដ្ឋានគ្រឹះនៃសន្តិសុខស្បៀងនៅកម្ពុជាដែលផ្តល់ប្រមាណបីភាគបួននៃប្រតេអ៊ីនសរុបពីជាតិសាច់ដែលប្រជាជនបរិភោគនៅទូទាំងប្រទេស(FAO 2011; IFReDI 2013)

តាមតួលេខប្រចាំឆ្នាំរបស់រដ្ឋបាលជលផលបង្ហាញថា ផលចាប់សរុបពីខេត្តទាំងបួនក្នុងតំបន់ឆ្នេរ មានការកើនឡើងប្រមាណ៣០% ចាប់ពីឆ្នាំ២០១០ រហូតដល់ឆ្នាំ២០១៧។ នេះបង្ហាញថា ប្រព័ន្ធអេកូឡូស៊ីសមុទ្ររបស់ប្រទេសកម្ពុជានៅមានភាពល្អប្រសើរនៅឡើយ។ តែទោះជាយ៉ាងនេះក្តី ការប្រើឧបករណ៍នេសាទខុសច្បាប់ ការបំផ្លាញជម្រកជលផល និងការបំពុលបរិស្ថាន គឺជាក្តីកង្វល់ធំបំផុតដែលនឹងបង្កភាពអវិជ្ជមានដល់ផលស្តុកធនធានជលផលហើយនិងប៉ះពាល់ដល់ផលចាប់និងប្រាក់ចំណូលដល់ប្រជានេសាទនាពេលអនាគត។ ខាងក្រោម គឺជាក្រាហ្វិកបង្ហាញពីតួលេខផលចាប់សរុបក្នុងតំបន់ឆ្នេរ។




Figure 2៖ ផលចាប់សរុបធនធានជលផលសមុទ្រប្រចាំឆ្នាំ

តាមការស្រាវជ្រាវរបស់រដ្ឋបាលជលផលបានបង្ហាញថា សមុទ្រកម្ពុជាមានធនធានជីវចម្រុះជាច្រើនប្រភេទ ជាពិសេសត្រីមាន៤៧៦ប្រភេទ ក្តាម២០ប្រភេទពពួកខ្យង៤២ប្រភេទនិងសិប្បិសត្វ២៤ប្រភេទ(Try 2003) ដែលប្រភេទទាំងនេះជាច្រើនមានតម្លៃខ្ពស់លើទីផ្សារ និងប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ការផលិតជាចំណីផ្គត់ផ្គង់វារីវប្បកម្មឬផលិតទឹកត្រី។

រដ្ឋបាលជលផលបានកំណត់យកប្រភេទធនធានជលផលសមុទ្រចំនួនជាង៥០ប្រភេទ ធ្វើជាសូចនាករសម្រាប់តាមដានពីប្រសិទ្ធភាពគ្រប់គ្រងធនធានជលផលនិងគុណភាពប្រព័ន្ធអេកូឡូស៊ី ប៉ុន្តែនៅក្នុងផែនការនេះ ក្រុមការងារបានជ្រើសរើសយកតែប្រភេទសំខាន់មួយចំនួនដូចបង្ហាញក្នុងតារាងទី២ ខាងក្រោម។

តារាងទី១៖ ប្រភេទផលសមុទ្រសំខាន់ៗដែលចាប់បានជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ២០១២ ដល់២០១៧
(ឯកត្តាគិតជាតោន)

| ប្រភេទផលនេសាទ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|
| ក្តាមសេះ | ៤០៩០ | ៤៣២៥ | ៦៧០០ | ៣៦២២ | ៥១២០ | ៤៩៤៦ |
| ក្តាមថ្ម | ៧៣២ | ៥៩៧ | ៩១៥ | ៦៦៣ | ៩៨០ | ៨៨៦ |
| មឹក | ៦២៤៨ | ៦.០៧១ | ៩.៤៧០ | ៥៦០៩ | ៥៩០៦ | ៦០០៦ |
| បង្គា | ៧.៧០៥ | ១១.១៩០ | ៨.៨០៦ | ៩១៧០ | ១២១៣៩ | ៩៨២២ |

| | | | | | | |
|---|---|---|---|---|---|---|
| ត្រីកាម៉ុង | ៣៣៣៦ | ៣៥០៤ | ៥២២៥ | ២៦៦៣ | ២៥៧៤ | ២៥២១ |
| ត្រីបេកា | ១២៣៤ | ១២៨៦ | ១៤៨៥ | ១៥០៦ | ១៥៣៩ | ១៥០៦ |
| ត្រីឆ្កង់ | ២៤៥ | ២៤០ | ២៦៥ | ៣១៥ | ៣៣៤ | ៣០៤ |
| ត្រីតុកកែ | ២៤៨ | ២៨២ | ៣២៥ | ២៨៩ | ៤៣៩៩ | ២៨៤ |
| ត្រីក្រហម | ២៨៣១ | ២៨៨៨ | ៣៦៣០ | ៣៤៣៦ | ៤៣៩៩ | ៤៤២៤ |
| គ្រែងឈាម | ១.៥៦៨ | ១.៨៦៦ | ២.៦០០ | ១៩២៥ | ២៣៧៥ | ២៣៩៦ |
| ត្រីជី | ៣៤.០៨៤ | ៣២.៩៨០ | ៤២.៧៧៣ | ៣៦៣៦៣ | ៤១៤១៤ | ៥១២៣៥ |

ប្រភព (ស្រង់ចេញពីរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលជលផល)

ដោយសារតែការទទួលរងសម្ពាធពីការនេសាទ ដែលមានការកើនឡើងជារៀងរាល់ឆ្នាំ ទើបធ្វើឱ្យប្រភេទធនធានជលផលមួយចំនួនបាននិងកំពុងទទួលរងគ្រោះថ្នាក់។ តាមការស្រាវជ្រាវរបស់រដ្ឋបាលជលផល មានប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់មានចំនួន២៩ប្រភេទ ដោយរួមទាំងពពួកត្រី ល្មូន និងថនិកសត្វផងដែរ ហើយប្រភេទទាំងនេះត្រូវបានកំណត់ដោយអនុក្រឹត្យលេខ១២៣ អនក្រ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៦ ដែលត្រូវមានវិធានការការពារនិងស្តារឡើងវិញជាបន្ទាន់។

តារាងទី២៖ ប្រភេទធនធានជលផលសមុទ្រដែលរងគ្រោះថ្នាក់នៅក្នុងប្រទេសកម្ពុជា

| ល.រ | ឈ្មោះក្នុងស្រុក | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះពាណិជ្ជកម្ម |
|---|---|---|---|
| ១ | ក្រពើសមុទ្រ | *Crocodylus porosus* | Estuarinecrocodile |
| ២ | ជ្រូកទឹក ឬពយ៉ុង | *Dugong dugon* | Dugong |
| ៣ | ត្រីសេកបូក | *Cheilinusundulates* | HumpheadWrasse |
| ៤ | បាឡែនក្របី | *Pseudorcacrassidens* | False killerwhale |
| ៥ | បាឡែនក្បាលធំ | *Globicephalamacrorhynchus* | Short-finnedpilot whale |
| ៦ | ផ្សោតច្រមុះដបចំពុះខ្លី | *Tursiopsaduncus* | Indo-Pacificbottlenosedolphin |
| ៧ | ផ្សោតក្បាលត្រងោល | *Orcaellabrevirostris* | Irrawaddydolphin |
| ៨ | ផ្សោតច្រមុះដបចំពុះវែង | *Tursiopstruncatus* | Commonbottlenosedolphin |
| ៩ | ផ្សោតឃ្លៀច | *Sousa chinensis* | Indo-Pacifichump-backeddolphin |
| ១០ | ផ្សោតឆ្នូតភ្នែក | *Stenella longirostrisroseinventris* | Dwarf spinnerdolphin |
| ១១ | ផ្សោតអុច | *Stenellaattenuata* | Pantropicalspotted dolphin |
| ១២ | ផ្សោតឥតព្រុយខ្នង | *Neophocaenaphocaenoides* | Finless porpoise |
| ១៣ | ផ្សោតខ្មៅលឿង | *Dolphinuscapensistropicalis* | Long-beakedcommon dolphin |
| ១៤ | ល្មិច | *Cheloniamydas* | Green turtle |
| ១៥ | ក្រាស | *Eretmochelysimbricata* | Hawksbill turtle |
| ១៦ | ល្មិចព្រុយបី ឬល្មិចស្លឹ | *Dermochelyscoriacea* | Leatherbackturtle |
| ១៧ | ល្មិចក្បាលធំ | *Caretta caretta* | Loggerheadturtle |

| | | | |
|---|---|---|---|
| ១៧ | ល្មិចប្រផេះ | *Lepidochelysolivacea* | Olive ridleyturtle |
| ១៩ | គ្រំយក្ស | *Tridacnasquamosa* | Fluted giantclam |
| ២០ | គ្រំយក្ស | *Tridacnamaxima* | Elongate giantclam |
| ២១ | គ្រំយក្ស | *Tridacnacrocea* | Crocus giant clam |
| ២២ | គ្រំយក្ស | *Tridacna gigas* | Giant clam |
| ២៣ | ខ្យងកោដ្ឋ | *Trochusniloticus* | Commercial top |
| ២៤ | ខ្យងគុជ ឬខ្យងប្រាក់ | *Turbomarmoratus* | Green turbo orgreen snail |
| ២៥ | សេះសមុទ្រ | *Hippocampus*spp. | Seahorse |
| ២៦ | ផ្កាថ្ម | *Anthozoa spp.* | Corals and seaanemones |
| ២៧ | ប្រទ្បាំងកាស | *Tachypleusgigas* | Triangular-tailhorseshoe crab |
| ២៨ | កាចរ | *Carcinoscorpius rotundicauda* | Mangrovehorseshoe crab |
| ២៩ | ត្រីបាណន់គីង្គក់ | *Rhincodontypus* | Whale shark |

## ១.៣ តំបន់ឆ្នេរខេត្តកែប

ខេត្តកែបមានទីតាំងស្ថិតនៅភាគនិរតី ជាប់នឹងសមុទ្រដែលមានចម្ងាយប្រមាណ១៧៥គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានផ្ទៃដីគោកទំហំសរុប១៨៧,២៤គីឡូម៉ែត្រក្រឡានិងមានកោះចំនួន១៣កោះ (កែប ២០១៥)។




Figure 3៖ ផែនទីខេត្តកែប

ខេត្តកែបមានស្រុក/ក្រុងចំនួន០២ ឃុំ/សង្កាត់ចំនួន០៥ ភូមិចំនួន១៨ និងមានចំនួនប្រជាពលរដ្ឋរស់នៅប្រមាណ៤១.១៧៧ ត្រូវជា៩៤៥៧គ្រួសារ (កែប ២០១៧)។ កែបជាខេត្តមួយដែលមានសក្តានុពលខ្ពស់លើវិស័យទេសចរណ៍ ដែលជាចំណូលដ៏សំខាន់បំផុតសម្រាប់លើកស្ទួយវិស័យសេដ្ឋកិច្ចនិងការអភិវឌ្ឍ។ ប្រជាពលរដ្ឋក្នុងខេត្តកែបមានមុខរបរពឹងផ្អែកលើធនធានធម្មជាតិ ដូចជាវិស័យទេសចរណ៍ធម្មជាតិ ការនេសាទការធ្វើស្រែអំបិល និងការធ្វើស្រែចំការ។

កែបជាទីក្រុងស្អាត បានទទួលពានរង្វាន់ផ្កាវិដ្ឋូល០៣ទង ចំនួន០២លើកជាប់គ្នា ក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត។ រាជរដ្ឋាភិបាលបានកំណត់ចក្ខុវិស័យខេត្តកែប ជាខេត្តទេសចរណ៍សម្រាកលំហែកំសាន្តប្រណិតកំរិតខ្ពស់ហើយក៏មិនបានអនុញ្ញាតឱ្យមានជារោងចក្រឧស្សាហកម្មធំៗឡើយ។ កន្លងមក ខេត្តកែបក៏បានទទួលនូវពានរង្វាន់និរន្តរភាពបរិស្ថានថ្នាក់អាស៊ាន ក្រោមប្រធានបទទឹកស្អាត ដីស្អាត និងខ្យល់ស្អាត ដែលប្រគល់នៅប្រទេសប្រ៊ុយណេនិងទទួលបានពានរង្វាន់ទីក្រុងទេសចរណ៍ស្អាតអាស៊ាន ដែលប្រគល់នៅខេត្តឈៀងម៉ៃនៃព្រះរាជាណាចក្រថៃព្រមជាមួយនោះ ខេត្តក៏កំពុងឈរជាបេក្ខភាពមួយទៀតក្នុងការប្រឡងប្រណាំង យកពានរង្វាន់ទីក្រុងជីវចម្រុះអាស៊ានចិន។

បច្ចុប្បន្ននេះ ដោយមានការអភិវឌ្ឍលើផ្នែកឧស្សាហកម្មនិងបច្ចេកវិទ្យាកាន់តែខ្លាំង ធ្វើឱ្យមានការកែច្នៃឧបករណ៍នេសាទកាន់តែទំនើប ដែលធ្វើឲ្យមានការបំផ្លាញដល់ធនធានជលផលរបស់យើងគួរឱ្យព្រួយបារម្ភ។

ឆ្នេរកែប មានប្រវែងប្រមាណ២៦,៥០គីឡូម៉ែត្រ មានកោះចំនួន១៣ គឺកោះពោធិ៍ កោះស្វាយព្រៃ កោះហាលត្រី កោះមាក់ប្រាង កោះអាចម៍សេះ កោះអង្រ្កង កោះស្ងួត កោះទន្សាយ កោះស្វាយ កោះគុក កោះម្ទេស កោះត្បាល់និងកោះការ៉ាង ស្ថិតនៅក្នុងដែននេសាទនៃភូមិសាស្ត្រក្រុងកែប និងស្រុកដំណាក់ចង្អើរ ខេត្តកែប។ កម្ពស់ទឹកសមុទ្រក្នុងដែនសមុទ្រខេត្តកែបគឺរាក់ មិនលើសពី១០ម៉ែត្រឡើយ បានផ្តល់នូវវត្តមានព្រៃកោងកាង ស្មៅសមុទ្រនិងផ្កាថ្មដ៏ស្រស់ស្អាត។

កោះពោធិ៍និងកោះទន្សាយ គឺជាកោះដែលមានសក្តានុពលខ្ពស់បំផុតក្នុងវិស័យជលផលនិងទេសចរណ៍ធម្មជាតិ ដោយសារកោះនេះសំបូរដោយធនធានធម្មជាតិយ៉ាងសំខាន់ ជាពិសេស ប្រព័ន្ធផ្កាថ្មនិងស្មៅសមុទ្រនៅជុំវិញកោះ ដែលជាជម្រកពងកូននិងរស់នៅរបស់មច្ឆជាតិច្រើនប្រភេទ ព្រមទាំងអាចទាក់ទាញទេសចរណ៍មកមុជកំសាន្តផងដែរ។

### *១.៣.១ ប្រជាសាស្ត្រ*

ធនធានធម្មជាតិក្នុងខេត្តកែប បានផ្តល់ឱកាសឱ្យប្រជាពលរដ្ឋទាញយកចំណូលដោយយូរអង្វែង ដើម្បីចិញ្ចឹមជីវិត។ ការទាញយកផលប្រយោជន៍ពីធនធានធម្មជាតិទាំងនេះរួមមាន ការនេសាទ ផលិតកម្មអំបិល និងការទាញយកផលអនុផលព្រៃឈើ។ ក្នុងការគ្រប់គ្រងធនធានទាំងនេះ ខេត្តមានមន្ទីរជំនាញនិងអង្គភាពក្រោមឱវាទបាននិងកំពុងធ្វើការងារយ៉ាងហ្មត់ចត់ក្នុងការកំណត់ព្រំប្រទល់តំបន់ព្រៃឈើ បោះបង្គោលកំណត់កន្លែងអភិរក្សរៀបចំនិងកំណត់ដែននេសាទ និងទប់ស្កាត់បទល្មើសផ្សេងៗ។

តាមការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា មានប្រជានេសាទប្រមាណ៦៨៤គ្រួសារ ដែលត្រូវជា៣៣០៤នាក់បាននិងកំពុងនេសាទជាប្រចាំនិងមិនពេញម៉ោងក្នុងតំបន់ឆ្នេរខេត្តកែប (រដ្ឋបាលជលផល ២០១៧) ជាពិសេសក្នុងតំបន់កោះពោធិ៍និងកោះទន្សាយ។ ប្រមាណជា៨០% នៃគ្រួសារអ្នកនេសាទទាំងអស់ បានធ្វើនេសាទជាលក្ខណៈគ្រួសារ ដោយប្រើលបមងក្តាម និងនេសាទដោយដៃដើម្បីប្រមូលគ្រុំ ងាវជាដើម។ តាមស្ថិតិរបស់រដ្ឋបាលជលផលឆ្នាំ២០១៧ បានបង្ហាញថា អ្នកនេសាទក្នុងខេត្តកែបនិយមប្រើមងក្តាម (៣៥០០០ម៉ែត្រ) លបក្តាម (៧០០០លប)

មងបង្គា (៥០០០ម៉ែត្រ) មងត្រីក្បក (៦០០០) ផ្ទាក់មឹកសំបកខ្យង (២០០០០ផ្ទាក់) ។ល។ ហើយក្រៅពីនេះ នៅមានប្រើទូកអូសដោយប្រើម៉ាស៊ីនចំនួន៤២វង់។

*១.៣.២ ធនធានសមុទ្រនៃខេត្តកែប*

ប្រព័ន្ធអេកូឡូស៊ីបាតសមុទ្រដូចជាផ្កាថ្មនិងស្មៅសមុទ្រនៃខេត្តកែប គឺជាជម្រកនៃប្រភេទសត្វសមុទ្រជាច្រើនប្រភេទដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ ដូចជា ក្តាមសេះ ត្រីតុកកែ ព្រមទាំងប្រភេទធនធានជលផលដែលជិតផុតពូជមួយចំនួន។

តារាងទី៣៖ ប្រភេទធនធានជលផលសំខាន់ដែលប្រមូលបានក្នុងតំបន់ឆ្នេរខេត្តកែប

| | ឈ្មោះខ្មែរ | ឈ្មោះពាណិជ្ជកម្ម | ឈ្មោះវិទ្យាសាស្ត្រ | អ្នករកឃើញ |
|---|---|---|---|---|
| ១ | ត្រីអណ្តាតឆ្កែ | Harrowed Sole | *Strabozebrians cancellatus* | McCulloch, 1916 |
| ២ | ត្រីសេក | Tripletail | *Cheilinus trilobatus* | Lacepede, 1801 |
| ៣ | ត្រីកន្តាំងថ្ម | Streaked spinefoot | *Singanus javus* | Linnaeus, 1766 |
| ៤ | ត្រីកន្តាំងក្រអូប | Whitesspotted spinefoot | *Singanus canaliculatus* | Park, 1797 |
| ៥ | ត្រីចិន | | *Saurida spp* | |
| ៦ | ត្រីក្រហម | | *Nemipterus spp* | |
| ៧ | ត្រីកន្តាំងភ្លើង | Orangespotted spinefoot | *Singanus guttatus* | Bloch, 1787 |
| ៨ | ត្រីតុកែក្រហមអុចខៀវ | Coral trout | *Plectropomus leopardus* | Lacepede, 1802 |
| ៩ | ត្រីតុកែជ្រូក | Humpback grouper | *Cromileptes altivelis* | Valenciennes, 1828 |
| ១០ | ត្រីក្បកកោងកាង | Bluespot grey mullets | *Valamugil seheli* | Forsskal, 1775 |
| ១១ | ត្រីផ្ទោងសមុទ្រ | | *Strongylura spp.* | |
| ១២ | ត្រីជី | Trash fish | | |
| ១៣ | ក្តាមសេះ | Flower crab or swimming crab | *Portunus pelagicus* | Fabricius, 1798 |
| ១៤ | ក្តាមថ្ម | Giant mud crab | *Scylla serrata* | Forsskal, 1775 |
| ១៥ | បង្គាកុងឡាយ | | *Penaeus esculentus* | |
| ១៦ | បង្គាអាងខា | | *Penaeus penicillatus* | |
| ១៧ | បង្គាខ្លឹង | Tiger shrimp | *Penaeus monodon* | |
| ១៨ | ខ្យងជើងមួយ | Dog conch | *Strombus canarium* | Linnaeus, 1758 |
| ១៩ | ខ្យងត្នោត | Nodle volute | *Cymbiola nobilis* | Lightfoot, 1786 |
| ២០ | គ្រំចំពុះទា | Green mussel | *Perna viridis* | Linnaeus, 1758 |
| ២១ | ត្រីឆ្លាម | Spottail shark | *Carcharhinus sorrah* | |
| ២២ | ត្រីអណ្តែងប៉ុយ | Sailfin catfish | Paraplotosus butleri | |
| ២៣ | ត្រីការ៉ាវ | Indian threadfin | *Polydactylus indicus* | |
| ២៤ | ត្រីព្រលួស | Oriental sillago | *Sillago Aeolus* | |

តួលេខផលចាប់សរុបមុនឆ្នាំ២០១៥ មិនត្រូវបានបង្ហាញដាច់ដោយឡែករវាងខេត្តកែបនិងកំពតទេ ដោយសារមុនឆ្នាំ២០១៥នេះ ខណ្ឌរដ្ឋបាលជលផលកែបមិនទាន់ត្រូវបានបង្កើតនៅឡើយ ដោយគ្រាន់តែជាផ្នែកមួយនៃខណ្ឌរដ្ឋបាលជលផលកំពតតែប៉ុណ្ណោះ។ ដោយឃើញពីសក្តានុពលនៃធនធានជលផលខេត្តកែប ទើបក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចផ្តាច់ផ្នែកជលផលកែបចេញពីខណ្ឌរដ្ឋបាលជលផលកំពត ហើយបង្កើតទៅជាខណ្ឌរដ្ឋបាលជលផលកែបពេញលេញ នៅក្នុងឆ្នាំ២០១៥នេះ។

ទោះជាយ៉ាងនេះក្តី ដោយសារតំបន់ឆ្នេរខេត្តកែបមានវិសាលភាពតូចជាងខេត្តទាំងបីទៀត ទើបផលនេសាទប្រចាំឆ្នាំសរុបតិចជាងខេត្តដទៃ ហើយម្យ៉ាងទៀត ផលចាប់សរុបមានការថយចុះចាប់ពីឆ្នាំ២០១៥ រហូតដល់បច្ចុប្បន្ន។ តារាងទី៤ ខាងក្រោមបង្ហាញពីផលចាប់សមុទ្រសរុបតាមខេត្តក្នុងតំបន់ឆ្នេរចាប់ពីឆ្នាំ២០១៥ដល់២០១៨។

**តារាងទី៤៖ ផលចាប់សរុបប្រចាំឆ្នាំតាមខេត្ត (គិតជាតោន)**

| ឆ្នាំ | កែប | កំពត | ព្រះសីហនុ | កោះកុង | សរុប |
|---|---|---|---|---|---|
| ២០១៥ | ២ ៦៨៣ | ១៥៥០០ | ៥៤០០០ | ៥១០០០ | ១២២៧៣៧ |
| ២០១៦ | ៤ ៧៧៣ | ២៣១៨០ | ៤៦០០០ | ៥០០៥០ | ១២០៦០០ |
| ២០១៧ | ៥ ១៨០ | ២១៦៤៥ | ៤៧៧៩០ | ៥០១៩០ | ១២១០២៥ |
| ២០១៨ | ៥ ២៩០ | ២១៦៦០ | ៤៧៨២០ | ៥០២១០ | ១២១១០០ |

ខាងក្រោម គឺជាតួលេខផលចាប់តាមប្រភេទសំខាន់ៗចាប់ពីឆ្នាំ២០១៥ដល់២០១៨ ក្នុងខេត្តកែប

**តារាងទី៥៖ ផលចាប់តាមប្រភេទសំខាន់ៗប្រចាំឆ្នាំខេត្តកែប (គិតជាតោន)**

| ប្រភេទផលនេសាទ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|
| ក្តាមសេះ | ៥០០ | ៥៨០ | ៦៥០ | ៧៥០ |
| ក្តាមថ្ម | ២.៥០ | ៣ | ៥ | ៥ |
| មឹក | ១៧០ | ១២០ | ១៥០ | ១៦០ |
| បង្គា | ៣០០ | ៣៥០ | ៤០០ | ៥០០ |
| ត្រីកាម៉ុង | ៥ | ៦ | ៧ | ៧ |
| ត្រីបេកា | ១ | ២ | ២ | ៣ |
| ត្រីឆ្លង់ | ១ | ២ | ៤ | ៥ |
| ត្រីតុកកែ | ២ | ៣ | ៣ | ៤ |
| ត្រីក្រហម | ១ | ៣ | ៥ | ៥ |
| គ្រែងឈាម | | ១ | ២ | ២ |

*(ប្រភពៈរបាយការណ៍រដ្ឋបាលជលផលកែបឆ្នាំ២០១៨)*

ផលក្តាមសេះដែលប្រមូលបានមានការប្រែប្រួលទៅតាមរដូវ ដូចជារដូវវស្សា អ្នកនេសាទអាចប្រមូលបានពី៥០ទៅ៦០គីឡូក្រាម/ថ្ងៃ/គ្រួសារ ឯនៅរដូវប្រាំង ពួកគេអាចប្រមូលបានត្រឹមតែពី២០ទៅ៣០គីឡូក្រាម/ថ្ងៃ/គ្រួសារ (Vibol 2017)។

តំបន់ឆ្នេរខេត្តកែប គឺបានបង្ហាញយ៉ាងច្បាស់ពីសក្ដានុពលរបស់ធនធានជលផលមួយចំនួនកំពុងរស់នៅនិងឆ្លងកាត់(MCC 2016) ដោយសារតែប្រព័ន្ធអេកូឡូស៊ីសមុទ្រក្នុងខេត្តកែបស្ថិតក្នុងស្ថានភាពល្អប្រសើរនៅឡើយ បើទោះបីជាមានការគំរាមកំហែងដោយសកម្មភាពនេសាទខុសច្បាប់ខ្លះក៏ដោយ។ ជាក់ស្ដែងប្រភេទដែលបានជួបប្រទះមានដូចជាផ្សោត (រួមទាំងផ្សោតក្បាលត្រឡោកនិងផ្សោតឆ្នូតភ្នែក) សេះសមុទ្រ ជ្រូកទឹក ល្មិចក្រាសល្មិចព្រុយបី ខ្យងកោជ និងគ្រុំយក្ស។ មានការរាយការណ៍ថា មានអត្រាជ្រូកទឹក(សមុទ្រ)ខ្ពស់ផងដែរ ហើយម៉្យាងទៀតតាមការស្រាវជ្រាវដោយអង្គការMCCក្នុងឆ្នាំ២០១៧ បានបង្ហាញថា មានផ្សោតប្រមាណពី៣០ទៅ ៤០ក្បាល មានវត្តមានក្នុងតំបន់ប្រជុំកោះពោធិ៍និងកោះទន្សាយ។

ការនេសាទដែលមានលក្ខណៈបំផ្លិចបំផ្លាញនិងការនេសាទហួសកម្រិតបានគំរាមកំហែងដល់ការរស់នៅរបស់អ្នកនេសាទខ្នាតតូចដែលរស់នៅក្នុងភូមិនេសាទ។ផលប៉ះពាល់អវិជ្ជមានទាំងនេះបានបណ្ដាលឱ្យបរិមាណចាប់មានកម្រិតកាន់តែទាបនិងជីវភាពរស់នៅរបស់អ្នកនេសាទខ្នាតតូចមានការលំបាក។

*១.៣.៣ប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ឆ្នេរខេត្តកែប (ប្រជុំកោះពោធិ៍និងកោះទន្សាយ)*

**ផ្កាថ្ម**

បណ្ដុំផ្កាថ្មបង្កើតជាបរិស្ថានធម្មជាតិបាតសមុទ្រមួយប្រកបដោយទស្សនីយភាពយ៉ាងល្អប្រណិត និងទាក់ទាញបំផុត។ ក្នុងតំបន់ត្រូពិក ផ្កាថ្មមានពណ៌ដ៏ស្រស់បំព្រងនិងទម្រង់ដ៏សាំញ៉ាំរបស់ផ្កាថ្មបានផ្ដល់ជាជម្រកដ៏សំខាន់ដល់ការរស់នៅនិងពងកូនរបស់មច្ឆជាតិនិងសត្វសមុទ្រជាច្រើនប្រភេទ។

ទន្ទឹមនឹងនេះ ប្រជុំកោះខេត្តកែបក៏មានពពួកផ្កាថ្មរឹងជាច្រើន ដែលបង្កើតជាតំបន់ផ្កាថ្មដ៏ធំធេង។ តាមការស្រាវជ្រាវដោយរដ្ឋបាលជលផលក្នុងឆ្នាំ២០០៥បានបង្ហាញថា នៅក្នុងតំបន់ឆ្នេរខេត្តកែប មានតំបន់ផ្កាថ្មសរុបប្រហែល៥២,៥០ហិកតា ជាពិសេសនៅតាមឆ្នេរនៃកោះពោធិ៍ កោះអាចម៍សេះ កោះត្បាល់ និងកោះស្វាយព្រៃ។ នៅផ្នែកខាងលិចនិងខាងជើងនៃកោះពោធិ៍ ផ្កាថ្មស្ថិតក្នុងស្ថានភាពល្អប្រសើរ និងមានហ្វូងត្រីជាច្រើនរស់នៅ ហើយនៅចន្លោះកោះស្វាយព្រៃនិងកោះពោធិ៍ ផ្កាថ្មក៏ស្ថិតក្នុងស្ថានភាពប្រសើរផងដែរ(Vibol 2017)។ ជាទូទៅ ផ្កាថ្មក្នុងតំបន់ប្រជុំកោះ ខេត្តកែប ផ្កាថ្មត្រូវបានគ្របដណ្ដប់ដោយកករជាច្រើន ដោយសារដែនសមុទ្រខេត្តកែប ជាតំបន់ទឹករាក់ បាតសមុទ្រភាគច្រើនជាប្រភេទភក់លាយខ្សាច់ និងសកម្មភាពទូកអូសក្នុងតំបន់ទឹករាក់បានបំភាយកករដីចូលទៅក្នុងតំបន់ផ្កាថ្ម។

**ស្មៅសមុទ្រ**

ល្បាប់ភក់ខ្មៅលាយជាមួយនឹងខ្សាច់ គឺជាបរិស្ថានមួយដ៏ល្អប្រសើរសម្រាប់ពពួកស្មៅសមុទ្ររស់នៅនិងលូតលាស់។ ស្មៅសមុទ្រ គឺជាប្រភេទរុក្ខជាតិដែលមានផ្កា ហើយដុះនៅបាតសមុទ្រតាមតំបន់ឆ្នេរ។ ស្មៅសមុទ្រដុះលូតលាស់នៅបាតសមុទ្រ ដោយដុះត្រង់ឡើងលើមានស្លឹក និងមានឫសចាក់ចូលទៅក្នុងដីបាតសមុទ្រ។ នៅលើពិភពលោកនេះ មានស្មៅសមុទ្រប្រមាណ៦០ប្រភេទ ដែលភាគច្រើនមានឃើញនៅតំបន់ត្រូពិកនៃមហាសមុទ្រប៉ាស៊ីហ្វិកភាគខាងលិច។ ចំណែកនៅតំបន់ឆ្នេរសមុទ្រកម្ពុជា ស្មៅសមុទ្រមានចំនួនប្រហែល១២ប្រភេទ ដែលភាគច្រើនជាពពួកស្មៅខ្លុយ ហើយតំបន់ដែលសម្បូរស្មៅសមុទ្រធំជាងគេ គឺតំបន់ឆ្នេរនៃខេត្តកំពតនិងខេត្តកែប (Vibol 2010)។

ស្មៅសមុទ្រជាអាហារយ៉ាងសំខាន់បំផុតសម្រាប់ប្រភេទសត្វជិតផុតពូជ ដូចជាអណ្ដើកសមុទ្រ ជ្រូកទឹកនិងប្រភេទសត្វផ្សេងៗទៀត។ តំបន់ស្មៅសមុទ្រជាជម្រកកន្លែងរកចំណីកន្លែងពងកូនរបស់ពពួកត្រីនិងវារីសត្វជាច្រើនប្រភេទដូចជាពពួកត្រីតុកកែត្រីកន្ទាំងត្រីសេកក្ដាមសេះបង្គាខ្យងគ្រំនិងឈ្លើងសមុទ្រ។ល។ តំបន់ស្មៅសមុទ្រក៏បានជួយរក្សាគុណភាពទឹកដោយវាទប់ការហូរច្រោះតាមតំបន់ឆ្នេរនិងទប់ស្កាត់នូវកករបាតដី ព្រមទាំងបានស្រូបយកជាតិ

ពុលផ្សេងៗពីភក់ទឹក និងបរិយាកាសផងដែរ។ តាមការវិភាគលើសក្តានុពលសេដ្ឋកិច្ចផ្នែកជលផលតែមួយមុខគឺស្មៅសមុទ្របានផ្តល់ផលគិតជាទឹកប្រាក់ប្រមាណជាង១.000ដុល្លា/ហិកតា/ឆ្នាំ ដោយមិនគិតញ្ចូលការប្រមូលសារាយ និងប្រភេទសត្វគ្មានឆ្អឹងកងផង ហើយបើគិតតម្លៃស្មៅសមុទ្រក្នុងខេត្តកែបទាំងមូល នោះអាចផ្តល់ជាថវិកាប្រមាណជាង៣លានដុល្លា/ឆ្នាំៗ(គិតតែលើផលត្រីដែលចាប់បានពីក្នុងតំបន់សមុទ្រ)។ ដោយឡែក តាមឯកសារ Seagrass in the South China Sea (2004)បានបង្ហាញថា នៅប្រទេសថៃ ស្មៅសមុទ្របានផ្តល់តម្លៃផ្ទាល់ជាថវិកាប្រមាណ២ទៅ៦,៣លានបាត/ឆ្នាំៗ (គិតជាតម្លៃចាប់ធនធានជលផលពីក្នុងតំបន់ស្មៅសមុទ្រ) ស្មៅសមុទ្រនៅប្រទេស ចិន ផ្តល់តម្លៃប្រមាណUSD ១៦.៦៤០-១៨.៣៨៥ ក្នុងមួយហិកតាហើយនៅក្នុងភូមិមួយនៃប្រទេសវៀតណាម ស្មៅសមុទ្របានផ្តល់តម្លៃផ្ទាល់USD ២៣.០០០ ក្នុងរយៈពេល៦ខែ (តម្លៃផលចាប់ធនធានជលផលក្នុងតំបន់ស្មៅសមុទ្រ)។

នៅក្នុងតំបន់ឆ្នេរនៃខេត្តកែប ស្មៅសមុទ្រមានដុះស្ទើរគ្រប់ទីកន្លែង ដោយសារតែគុណភាពដីដ៏ល្អប្រសើរហើយបានជួយឱ្យប្រព័ន្ធអេកូឡូស៊ីស្មៅសមុទ្រនេះក្លាយជាជម្រកដ៏មានតម្លៃបំផុត។ តាមការស្រាវជ្រាវរបស់រដ្ឋបាលជលផលក្នុងឆ្នាំ២០០៥ បានបង្ហាញថា តំបន់ស្មៅសមុទ្រក្នុងតំបន់ឆ្នេរខេត្តកែប មានទំហំសរុបប្រហែល៣០៩៥ហិកតា ហើយទីតាំងដែលមានវិសាលភាពស្មៅសមុទ្រធំជាងគេ គឺចន្លោះកោះទន្សាយនិងកែប (២៧៩០ហិកតា) ហើយក្រៅពីនេះមាននៅកោះពោធិ៍ ទំហំ៦៣ហិកតា កោះទន្សាយទំហំ២២៩ហិកតា និងកោះត្បាល់ទំហំ១៣ហិកតា។ តាមការស្រាវជ្រាវថ្មីៗនេះដោយអង្គការអភិរក្សកម្ពុជា បានបង្ហាញថា ស្មៅសមុទ្រក្នុងតំបន់កោះពោធិ៍គ្របដណ្តប់ប្រមាណ៤៥៦ហិកតា កោះទន្សាយប្រមាណ២៦១ហិកតា និងកោះសេះ៣៨ហិកតា។ ក្នុងចំណោមប្រភេទសមុទ្រ១២ប្រភេទ ដែលមានវត្តមានក្នុងតំបន់ឆ្នេរនៃប្រទេសកម្ពុជាមានស្មៅសមុទ្រ៩ប្រភេទ មានវត្តមានក្នុងតំបន់ឆ្នេរខេត្តកែប។

ការបំផ្លាញស្មៅសមុទ្រដោយសកម្មភាពនេសាទខុសច្បាប់ការបោះចោលកាកសំណល់រឹងរាវ និងការសាងសង់សំណង់ផ្សេងៗនៅលើតំបន់នេះនឹងធ្វើឱ្យមានការបាត់បង់ទីជម្រកកន្លែងរកចំណីកន្លែងពងកូនកន្លែងរស់នៅធំធាត់របស់ត្រី និងរ៉ាវីសត្វផ្សេងៗនិងប្រភេទសត្វដែលកំពុងរងគ្រោះថ្នាក់និងនាំឱ្យប៉ះពាល់ដល់ផលស្តុកក្នុងតំបន់ឆ្នេរហើយទីបំផុតនឹងជះឥទ្ធិពលដល់ការរស់នៅចិញ្ចឹមជីវិតរបស់ប្រជាជនតំបន់ឆ្នេរ។

## ព្រៃកោងកាង

ព្រៃកោងកាងត្រូវបានទទួលស្គាល់ថា មានសារៈប្រយោជន៍បំផុតសម្រាប់ប្រជាពលរដ្ឋនៅតាមតំបន់ឆ្នេរដោយព្រៃនេះមានមុខងារជាច្រើនប្រភេទ ដូចជាផ្តល់ធនធានជលផលសម្រាប់ការនេសាទ ជាកន្លែងពងកូនរបស់សត្វជាច្រើនប្រភេទ ទប់ស្កាត់ការហូរច្រោះ ទប់ស្កាត់ខ្យល់ព្យុះ ស្តុកកាបោន និងជាតំបន់ទេសចរណ៍ដ៏ទាក់ទាញផងដែរ។ តាមការស្រាវជ្រាវរបស់រដ្ឋបាលជលផល បានបង្ហាញថា ព្រៃកោងកាងសរុបក្នុងតំបន់ឆ្នេរមានទំហំប្រហែល៦២.០០០ហិកតា ដោយក្នុងនោះ ខេត្តកែបមានទំហំ១.០០៥ហិកតា។ តាមតួលេខនេះបានបញ្ជាក់ថា ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ព្រៃកោងកាងបានថយចុះក្នុងចន្លោះ៣០ទៅ៤០%។ កត្តាដែលធ្វើឱ្យធ្លាក់ចុះ គឺដោយសារការចាប់យកដីជាកម្មសិទ្ធ ការពង្រីកផលិតកម្មអំបិល និងការអភិវឌ្ឍផ្សេងៗនៅតាមតំបន់ឆ្នេរ។




Figure 4៖ របាយប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ឆ្នេរខេត្តកែប

*១.៣.៤ ការគំរាមកំហែង (Threats)*

កែបជាតំបន់មួយនៃតំបន់ ដែលមានផលិតភាពនៃជីវៈចម្រុះច្រើនក្នុងតំបន់អាស៊ីអាគ្នេយ៍។ តំបន់ស្មៅសមុទ្របានថយចុះប្រមាណ២០%ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។ ម្យ៉ាងទៀត ជម្រកផ្សេងៗក៏កំពុងតែរងផលប៉ះពាល់ផងដែរ ដោយសារមានការនេសាទខុសច្បាប់និងកត្តាធម្មជាតិ ដែលនាំឱ្យផលនេសាទដែលមានតម្លៃដូចជាក្ដាមត្រី និងបង្គាជាដើម ក៏បានថយចុះដែរ។

តាមការស្រាវជ្រាវនៃការគំរាមកំហែងបានឱ្យដឹងថា កត្តាដែលធ្វើឱ្យធនធានជលផលធ្លាក់ចុះ គឺដោយសារសកម្មភាពនេសាទខុសច្បាប់ ការនេសាទហួសកម្រិត ការបំផ្លាញទីជម្រកជលផល ភាពក្រីក្រ ការបំពុលបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។

ការប្រើអួនអូសក្នុងតំបន់ទឹករាក់ ក៏បានប៉ះពាល់ជាអវិជ្ជមានផងដែរទៅលើតំបន់ផ្កាថ្ម ដោយសារការអូសនៅក្បែរតំបន់ផ្កាថ្ម បានបង្កើនកករគ្របទៅលើតំបន់ផ្កាថ្ម ហើយជាបណ្ដើរៗ ផ្កាថ្មទាំងនោះមានសុខភាពពុំល្អ។

ក្ដាមសេះដែលជាប្រភេទជលផលនេសាទពាណិជ្ជកម្មដ៏មានតម្លៃមួយ និងធ្លាប់តែមានអត្រាខ្ពស់ ប៉ុន្តែបច្ចុប្បន្នកំពុងមានការធ្លាក់ចុះ។ នៅឆ្នាំ២០០៦មានទូកអួនអូសចំនួនប្រមាណ១០គ្រឿងប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្ននេះមានទូកអួនអូសជាង៥០គ្រឿងបាននិងកំពុងធ្វើនេសាទក្នុងដែនសមុទ្រខេត្តកែប។ ច្បាប់ជលផលរបស់ប្រទេសកម្ពុជាបានហាមឃាត់ការនេសាទអួនអូសនៅតំបន់ដែលមានជម្រៅទឹករាក់ជាង២០ម៉ែត្រ។ ការនេសាទខុសច្បាប់

ទាំងនេះ បាននិងកំពុងបង្កផលប៉ះពាល់ដល់ការនេសាទជាលក្ខណៈគ្រួសារនិងប្រភេទសត្វដែលជិតផុតពូជ ដូចជា សេះសមុទ្រ សត្វផ្សោត ជ្រូកទឹក បាឡែន ឆ្លាម អណ្តើកសមុទ្រ និងត្រីយក្ស ជាដើម។

*១.៣.៥ កិច្ចការពារនាបច្ចុប្បន្ន*

ខណ្ឌរដ្ឋបាលជលផលកែប ត្រូវបានបង្កើតឡើងនាឆ្នាំ២០១៥ ដែលមានតួនាទីទទួលខុសត្រូវនិងធ្វើសកម្មភាព ដោយផ្ទាល់លើដែននេសាទទាំងមូលក្នុងខេត្ត ជាពិសេសការត្រួតពិនិត្យបទល្មើស។ ខណ្ឌរដ្ឋបាលជលផលកែប មានរចនាសម្ព័ន្ធត្រឹមត្រូវ ដែលមានផ្នែកមួយទទួលខុសត្រូវលើការត្រួតពិនិត្យបទល្មើសច្បាស់លាស់ ព្រមទាំងមាន សកម្មភាពលើផ្ទៃសមុទ្រដ៏សកម្ម។ ប៉ុន្តែបញ្ហាចោទចំពោះមុខ គឺមន្ត្រីបម្រើការក្នុងអង្គភាពនេះមានចំនួនតិចនិងខ្វះ ខាតមធ្យោបាយ និងថវិកា ក្នុងការគ្រប់គ្រងនិងបង្ក្រាបបទល្មើសជលផល ដែលធ្វើឱ្យការគ្រប់គ្រងធនធានជលផល នៅមិនទាន់មានប្រសិទ្ធភាពនៅឡើយ។

នៅឆ្នាំ២០១៧ រចនាសម្ព័ន្ធរបស់រដ្ឋបាលជលផល បានកែសម្រួលពីប្រព័ន្ធខ្សែបណ្តោយមកប្រព័ន្ធខ្សែទទឹង វិញ គឺមានន័យថា ខណ្ឌរដ្ឋបាលជលផលកែបត្រូវបានដាក់ឱ្យស្ថិតនៅក្រោមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រោយការកែសម្រួលប្រព័ន្ធរដ្ឋបាលនេះមក រដ្ឋបាលជលផលថ្នាក់កណ្តាលពុំមានសិទ្ធិបញ្ជាផ្ទាល់ទៅខណ្ឌ រដ្ឋបាលជលផលកែបឡើយ ប៉ុន្តែរដ្ឋបាលជលផល ដែលមាននាយកដ្ឋាននិងវិទ្យាស្ថានជំនាញ តែងជួយសម្រប សម្រួលការងារបច្ចេកទេស និងស្វែងរកថវិកាពីដៃគូនានាសម្រាប់ជួយដល់សកម្មភាពការងាររបស់ខណ្ឌរដ្ឋបាលជល ផលខេត្ត តាមរយៈមន្ទីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ឬដោយផ្ទាល់ ក្នុងករណីចាំបាច់។

ដើម្បីសម្រួលដល់ការគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ គោលនយោបាយក្នុងការបង្កើតឱ្យមានសហគមន៍នេសាទ។ រហូតមកដល់សព្វថ្ងៃនេះ ខេត្តកែបបានបង្កើតសហគមន៍ នេសាទចំនួន០៥ហើយ។

នាយកដ្ឋានអភិរក្សជលផល មានតួនាទីសិក្សា សម្របសម្រួលបង្កើត និងគ្រប់គ្រងកន្លែងអភិរក្សជលផលនៅ ទូទាំងប្រទេស។ នៅក្នុងខេត្តកែប ក្រោមកិច្ចសហការរវាងនាយកដ្ឋានអភិរក្សជលផលនិងខណ្ឌរដ្ឋបាលជលផល កែបនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដោយមានការគាំទ្រពីរដ្ឋបាលខេត្តកែបផងនោះ តំបន់គ្រប់គ្រង ជលផលនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប (MFMA-Kep) ត្រូវបានបង្កើតឡើង ដើម្បីជួយធានាដល់ និរន្តរភាពធនធានជលផលក្នុងខេត្តកែប។ ហើយតទៅមុខទៀត នាយកដ្ឋានអភិរក្សជលផលនឹងបន្តសហការជាមួយ ខណ្ឌរដ្ឋបាលជលផលកែប ក្រោមការផ្តល់អនុសាសន៍ពីរដ្ឋបាលជលផលនិងរដ្ឋបាលខេត្តកែប ដើម្បីជួយកៀងគររក ថវិកានិងជួយគាំទ្របច្ចេកទេសក្នុងគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រក្នុងខេត្តកែបនេះឱ្យមានប្រសិទ្ធភាព។

រចនាសម្ព័ន្ធគ្រប់គ្រង MFMA-Kepត្រូវបានបង្កើតរួចហើយដោយសេចក្តីសម្រេចរបស់រដ្ឋបាលខេត្តកែប។ រួមមានគណៈកម្មាការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប (PMC-MFMA-Kep) ដែលមានឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តកែបជាប្រធាន និងមានសមាសភាពជាសមាជិកមកពីរដ្ឋបាលជលផល និងថ្នាក់ខេត្ត ចំនួន២០រូបនិងក្រុមការងារបច្ចេកទេសតំបន់គ្រប់គ្រងជលផលខេត្តកែប (TWG-MFMA-Kep)ដែលមានអភិបាល រងនៃគណៈអភិបាលខេត្តកែបមួយរូបជាប្រធាន និងមានសមាសភាពមកពីរដ្ឋបាលជលផល ថ្នាក់ខេត្ត ថ្នាក់មូលដ្ឋាន សហគមន៍នេសាទ និងអង្គការដៃគូមួយចំនួន២៩រូប(សូមមើលក្នុងឧបសម្ព័ន្ធ២ ភ្ជាប់ជាមួយផែនការនេះ)។

## ២. តំបន់គ្រប់គ្រងជលផលសមុទ្រ

តំបន់គ្រប់គ្រងជលផលសមុទ្រ (Marine Fisheries Management Area- MFMA) ដែលភាសាផ្លូវការជា អន្តរជាតិហៅថា តំបន់ការពារសមុទ្រ(Marine Protected Area- MPA) ជាជម្រើសមួយដ៏ប្រសើរនិងត្រូវបាន

ទទួលស្គាល់ជាអន្តរជាតិ ថាអាចជួយក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត។ នៅឆ្នាំ ២០០៦ប្រទេសជាភាគីក្នុងអនុសញ្ញាស្តីពីជីវៈចម្រុះ (CBD) បានប្តេជ្ញាធ្វើការអភិរក្ស១០% នៃតំបន់អេកូឡូស៊ីពិភពលោកឱ្យមានប្រសិទ្ធភាពឱ្យបានមុនឆ្នាំ២០២០តាមរយៈចំណុចដៅ Aichi ទី១១ (CBD 2011)។ គោលដៅនៃចំណុចដៅ១១គឺយ៉ាងហោចណាស់ ១០% នៃតំបន់ឆ្នេរនិងសមុទ្រជាពិសេសកន្លែងនានាដែលមានសារៈសំខាន់សម្រាប់ជីវៈចម្រុះនិងសេវាកម្មប្រព័ន្ធអេកូឡូស៊ីត្រូវបានដាក់ក្រោមការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងដោយសមធម៌។

ក្រោយការសិក្សាលើស្ថានភាពនៃធនធានជលផលនិងសេដ្ឋកិច្ចសង្គមរួចមក ក្រុមការងាររបស់នាយកដ្ឋានអភិរក្សជលផលនៃរដ្ឋបាលជលផល សហការជាមួយខណ្ឌរដ្ឋបាលជលផលកែបនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកែប ដោយមានការគាំទ្រពីរដ្ឋបាលខេត្តកែប និងក្រោមការជួយឧបត្ថម្ភគាំទ្រទាំងបច្ចេកទេសនិងថវិកាពី MCC, IUCN/MFFនិងSEAFDEC/UNEP/GEF បានរៀបចំបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែបនេះឡើងដោយឆ្លងកិច្ចប្រជុំជាច្រើនលើកជាមួយប្រជានេសាទនិងអាជ្ញាធរមូលដ្ឋានចំនួន០៧លើក ប្រជុំថ្នាក់បច្ចេកទេសនៅថ្នាក់ខេត្តចំនួន០១លើក ប្រជុំពេញអង្គថ្នាក់ខេត្តចំនួន០១លើក និងប្រជុំថ្នាក់ជាតិចំនួន០២លើក ហើយទទួលបានការឯកភាពទាំងស្រុងលើសេចក្តីព្រាងប្រកាសនិងផែនទីបញ្ជាក់ពីតំបន់ដែលត្រូវបង្កើត។ ក្រោយមក សេចក្តីព្រាងប្រកាសនេះត្រូវបានអនុម័តនិងចុះហត្ថលេខាដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈប្រកាសលេខ១៩៣ប្រក.កសក ចុះថ្ងៃទី១២ខែមេសា ឆ្នាំ២០១៨ ដោយមានចំណងជើងថា ប្រកាសស្តីពីការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប។

តំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយខេត្តកែប មានវិសាលភាពគ្របដណ្តប់លើតំបន់ទឹកនៃកោះពោធិ៍ កោះស្វាយព្រៃ កោះហាលត្រី កោះមាក់ប្រាង កោះអាចម៍សេះ កោះអង្រុង កោះទន្សាយ កោះស្វាយ កោះកុក កោះម្ទេស និងកោះត្បាល់ស្ថិតនៅក្នុងដែននេសាទនៃភូមិសាស្ត្រក្រុងកែប និងស្រុកដំណាក់ចង្អើរ ខេត្តកែប ដែលមានផ្ទៃក្រឡាសរុប១១.៣០៧(ដប់មួយពាន់បីរយប្រាំពីរ)ហិកតា ដូចមានផែនទីបង្ហាញខាងក្រោម៖




Figure 5៖ ផែនទីតំបន់គ្រប់គ្រងជលផលក្នុងប្រជុំកោះពោធិ៍និងកោះទន្សាយខេត្តកែប

## ២.១ គោលបំណងនៃការបង្កើតMFMA

គោលបំណងនៃការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយខេត្តកែប គឺដើម្បីការពារ អភិរក្ស និងប្រើប្រាស់ធនធានជលផលសមុទ្រប្រកបដោយនិរន្តរភាព ស្របតាមគោលនយោបាយវិស័យជលផលជាតិនិងរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ តំបន់គ្រប់គ្រងមានគោលដៅ៖

- គ្រប់គ្រងនិងអភិរក្សធនធានជីវចម្រុះជលផល និងប្រព័ន្ធអេកូឡូស៊ីសមុទ្រឲ្យមានប្រសិទ្ធភាព
- ធានាបានការនេសាទប្រកបដោយនិរន្តរភាព ដើម្បីលើកស្ទួយជីវភាពប្រជាពលរដ្ឋ
- រួមចំណែកជំរុញវិស័យទេសចរណ៍ធម្មជាតិនិងការវិនិយោគនៅតំបន់កោះខេត្តកែប
- ពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

## ២.២ ការកំណត់តំបន់គ្រប់គ្រង

### *២.២.១ -កន្លែងអភិរក្សជលផល*

ត្រូវបានកំណត់ក្នុងភូមិសាស្ត្រ ដែលមានសក្តានុពលជាក់លាក់សម្រាប់វារីសត្វឬរុក្ខជាតិជ្រកពួន ពងកូន រីកធំធាត់ឬរីកលូតលាស់។ កន្លែងអភិរក្សជលផលពុំអាចអនុញ្ញាតឲ្យប្រព្រឹត្តសកម្មភាពគ្រប់ប្រភេទដែលនាំឱ្យមានផលប៉ះពាល់ដល់ធនធានជលផលបានឡើយ ក្រៅពីការស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល ដោយមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

*២.២.២-កន្លែងការពារធនធានជលផល*

ត្រូវបានកំណត់នៅទីតាំងជាប់ឬក្បែរកន្លែងអភិរក្សជលផលដែលមានមុខងារជាសំខាន់ជួយគាំទ្រដល់កន្លែងអភិរក្សជលផលដើម្បីធានានិរន្តរភាពធនធានជលផល។ កន្លែងការពារនេះអាចប្រើប្រាស់ជាកន្លែងនេសាទជាលក្ខណៈគ្រួសារនិងសកម្មភាពផ្សេងៗទៀតដែលពុំបំផ្លិចបំផ្លាញដល់ធនធានជលផលនិងជីវចម្រុះឡើយ។

*២.២.៣-ដែនជម្រកសុវត្ថិភាពជលផល*

ត្រូវកំណត់ក្នុងភូមិសាស្ត្រជាក់លាក់សម្រាប់ការពារប្រភេទវារីសត្វមួយឬច្រើន ក្នុងដំណាក់កាលនៃវដ្តជីវិតពិសេសរបស់វា។ ការធ្វើនេសាទឬសកម្មភាពផ្សេងៗនៅក្នុងដែនជម្រកសុវត្ថិភាពជលផលត្រូវបានហាមឃាត់ក្នុងរដូវកាលជាក់លាក់ហើយក្រោយរដូវកាលនេះ ការនេសាទជាលក្ខណៈគ្រួសារនិងសកម្មភាពផ្សេងទៀតដែលពុំប៉ះពាល់ជាអវិជ្ជមានដល់ធនធានជលផលអាចអនុញ្ញាតបានជាធម្មតា។

ដែនជម្រកសុវត្ថិភាពជលផលត្រូវបានកំណត់ចំនួនមួយកន្លែងក្នុងទីតាំងក្បែរកោះពោធិ៍ ដែលមានផ្ទៃក្រឡាសរុប៤១៧ហិកតា សម្រាប់អភិរក្សក្តាមសេះ ពីព្រោះទីតាំងនេះជាតំបន់ស្មៅសមុទ្រដ៏ស្តុកស្តម្ភ ហើយជាកន្លែងពងកូនរបស់ក្តាមសេះ។ ការទប់ស្កាត់ការបំផ្លាញស្មៅសមុទ្រក្នុងទីតាំងនេះ និងការបិទនេសាទក្តាមសេះ ចាប់ពីថ្ងៃទី០១ ខែឧសភា ដល់ទី៣១ កក្កដាជារៀងរាល់ឆ្នាំ អាចនឹងជួយធានាបានផលស្តុកនិងផលចាប់ក្តាមសេះក្នុងខេត្តកែប។

***២.២.៤-កន្លែងអេកូទេសចរណ៍បាតសមុទ្រ***

ត្រូវបានកំណត់ថា ជាតំបន់ដែលមានមុខងារសំខាន់សម្រាប់បម្រើឱ្យសកម្មភាពកំសាន្តនិងការពារប្រភពធនធានជីវចម្រុះ ដើម្បីធានាបានប្រាក់ចំណូលពីវិស័យទេសចរណ៍បាតសមុទ្រ និងនិរន្តរភាពធនធានជលផល។ កន្លែងនេះត្រូវបានអនុញ្ញាតសម្រាប់ការមុជទឹកកំសាន្តមើលផ្កាថ្ម និងធនធានជលផលដទៃទៀតប្រកប ដោយការទទួលខុសត្រូវព្រមទាំងសម្រាប់ការប្រមូលព័ត៌មានវិទ្យាសាស្ត្រ និងតាមដានបម្រែបម្រួលធនធានជលផល។ ការនេសាទគ្រប់ប្រភេទនៅក្នុងកន្លែងនេះត្រូវបានហាមឃាត់។

## ៣. ក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ

ក្របខណ្ឌច្បាប់អន្តរជាតិនិងច្បាប់ជាតិព្រមទាំងចំណុចដៅដែលពាក់ព័ន្ធជាមួយ MFMA ដែលបានស្នើឡើងសម្រាប់កម្ពុជាមានដូចតទៅ៖

1) យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
2) ច្បាប់ស្តីពីជលផល
3) គោលនយោបាយវិស័យជលផលជាតិ
4) ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល ២០១៥-២០២៤
5) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣
6) ព្រះរាជក្រឹត្យនិងអនុក្រឹត្យស្តីពីការបង្កើតនិងគ្រប់គ្រងសហគមន៍នេសាទ
7) អនុក្រឹត្យស្តីពីការកំណត់ប្រភេទផល ផលិតផលជលផលដែលរងគ្រោះថ្នាក់
8) យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ
9) ផែនការសកម្មភាពយុទ្ធសាស្ត្រជីវចម្រុះជាតិ
10) ប្រកាសស្តីពីការបង្កើតតំបន់គ្រប់គ្រងផលសមុទ្រប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប
11) ផែនការអភិវឌ្ឍខេត្តកែបរយៈពេល៥ឆ្នាំ (២០១៥-២០១៩)

12) ផែនការយុទ្ធសាស្រ្តសម្រាប់ការអភិរក្សនិងគ្រប់គ្រងធនធានជលផល ១០ឆ្នាំ (២០១៩-២០២៨)។

កម្ពុជាគឺជាហត្ថលេខីនៃកិច្ចព្រមព្រៀងអន្តរជាតិជាច្រើន។សន្ធិសញ្ញាដែលពាក់ព័ន្ធជាមួយវិស័យជលផល និងបរិស្ថាននៃដែនទឹកមានជាអាទិ៍៖

1) អនុសញ្ញាស្តីពីជីវចម្រុះ
2) សន្ធិសញ្ញាស្តីពីការនេសាទនិងការអភិរក្សធនធានមានជីវិតនៅដែនសមុទ្រអន្តរជាតិ
3) អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិនៃប្រភេទសត្វនិងរុក្ខជាតិរងគ្រោះថ្នាក់ (សាយតេស)
4) ពិធីសារក្យូតូនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
5) អនុសញ្ញាស្តីពីតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិជាពិសេសជាជម្រកសត្វស្លាបទឹក (អនុសញ្ញារ៉ាមសារ)
6) អនុសញ្ញាអន្តរជាតិសម្រាប់និយ័តកម្មការបរបាញ់សត្វបាឡែន
7) អនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រ (UNCLOS) - បានចុះហត្ថលេខាតែមិនផ្តល់សច្ចាប័ន
8) អនុសញ្ញាអន្តរជាតិសម្រាប់ទប់ស្កាត់ការបំពុលពីនាវា (MARPOL)

## ៤. ផែនការសកម្មភាព

### ៤.១ គោលដៅ

គោលដៅនៃផែនការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប គឺ *ធនធានជលផលនិងប្រព័ន្ធអេកូឡូស៊ីមានភាពប្រសើរឡើងតាមរយៈការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ដើម្បីធានាការប្រើប្រាស់ប្រកបដោយនិរន្តរភាពលើកកំពស់វិស័យទេសចរណ៍ធម្មជាតិនិងភាពធននឹងការប្រែប្រួលអាកាសធាតុរបស់សហគមន៍ ដែលរួមចំណែកដល់ការបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។*

គោលដៅនៃផែនការគ្រប់គ្រងនេះនឹងជួយសម្រេចឱ្យបាននូវគោលដៅរបស់ក្របខណ្ឌផែនការយុទ្ធសាស្រ្តជលផល ២០១៥-២០២៤ និងសូចនាករអនុកម្មវិធីទី១ នៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ ដែលមានចែងដូចខាងក្រោម:

តារាងទី៦៖ សូចនាករនៃអនុកម្មវិធីទី១ នៃវិស័យជលផល

| សូចនាករ | ឯកតា | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ១.ផលនេសាទចាប់ពីធម្មជាតិ | ពាន់តោន | ៦០០ | ៦០០ | ៦០០ | ៦០០ | ៦០០ |
| ២.ចំនួនសហគមន៍គ្រប់គ្រងប្រកបដោយប្រសិទ្ធភាព | ចំនួនសហគមន៍ | ១០០ | ១៥០ | ២០០ | ២៥០ | ៣០០ |
| ៣.ផ្ទៃកន្លែងអភិរក្សជលផលត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព | ពាន់ហិកតា | ១៣៦ | ១៤២ | ១៤៩ | ១៥៧ | ១៦៥ |

*ផែនការនេះក៏នឹងរួមចំណែកដល់ការសម្រេចបាននូវគោលដៅរបស់ផែនការយុទ្ធសាស្រ្តថ្នាក់ជាតិស្តីពីការអភិរក្សនិងគ្រប់គ្រងជលផល ២០១៩-២០២៨ ព្រមទាំងផែនការអភិវឌ្ឍន៍វិស័យកសិកម្មផងដែរ។*

### ៤.២ គោលបំណង

ផែនការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយខេត្តកែប សម្រាប់រយៈពេល៣ឆ្នាំមានគោលបំណងសំខាន់ចំនួន៦ ដើម្បីដោះស្រាយនិងកាត់បន្ថយរាល់ការគំរាមកំហែងដល់ទីជម្រកជលផលព្រមទាំងរក្សាឱ្យបាននូវតួនាទី មុខងារ និងតម្លៃសេដ្ឋកិច្ចរបស់ធនធាន រួមមាន៖

១. ពង្រឹងការអនុវត្តច្បាប់ ដើម្បីទប់ស្កាត់បទល្មើសនេសាទនិងបទល្មើសផ្សេងៗទៀតប្រកបដោយប្រសិទ្ធភាព។

២. ធ្វើឱ្យប្រសើរឡើងនូវការការពារនិងស្តារទីជម្រកសំខាន់ៗ ដើម្បីធានាបានផលស្តុកធនធានជលផលនៅក្នុងដែនទឹកធម្មជាតិប្រកបដោយប្រសិទ្ធភាព។

៣. បណ្តុះបណ្តាលនិងបង្កើនការយល់ដឹងជាសាធារណៈដល់មន្ត្រីជំនាញ សមាជិកសហគមន៍និងអ្នកពាក់ព័ន្ធផ្សេងទៀតអំពីតួនាទីតំបន់គ្រប់គ្រងជលផលតម្លៃប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងជីវចម្រុះជលផលដើម្បីជំរុញការគ្រប់គ្រងធនធានជលផលឱ្យប្រសើរឡើង។

៤. សិក្សាស្រាវជ្រាវនិងតាមដានត្រួតពិនិត្យស្ថានភាពទីជម្រក និងធនធានជលផលសំខាន់ៗដើម្បីជួយដល់ការងារការពារនិងអភិរក្សប្រកបដោយប្រសិទ្ធភាព។

៥. ធានាបាននិរន្តរភាពថវិកាក្នុងការគ្រប់គ្រង និងធ្វើឱ្យប្រសើរឡើងនូវមុខរបរចិញ្ចឹមជីវិតរបស់សហគមន៍នេសាទដើម្បីកាត់បន្ថយការដាក់សម្ពាធលើធនធានជលផល។

៦. ពង្រឹងយន្តការគ្រប់គ្រងចម្រុះ ដើម្បីធានាបានការគ្រប់គ្រងធនធានជលផលក្នុងតំបន់គ្រប់គ្រងជលផលខេត្តកែបប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ៤.៣ សកម្មភាពមេដែលសម្រេចគោលបំណង

តម្រូវការសកម្មភាពសំខាន់ៗដើម្បីសម្រេចឱ្យបាននូវគោលបំណងនីមួយៗ ត្រូវបានដាក់ចេញដូចខាងក្រោម។ ការអនុវត្តសកម្មភាពនេះ នឹងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការការពារនិងអភិរក្សធនធានជលផល ដើម្បីជំរុញតុល្យភាពរវាងការប្រើប្រាស់និងការអភិរក្ស ហើយធានាបានថា ផលប្រយោជន៍នៃការប្រើប្រាស់ប្រកបដោយនិរន្តរភាពនេះបានរួមចំណែកកាត់បន្ថយភាពក្រីក្រនិងធ្វើឱ្យប្រសើរឡើងកំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា។ សកម្មភាពសំខាន់ដើម្បីសម្រេចឱ្យបាននូវគោលបំណងទាំង៩ មានដូចខាងក្រោម៖

<u>គោលបំណងទី១</u>- ពង្រឹងការអនុវត្តច្បាប់ ដើម្បីទប់ស្កាត់បទល្មើសនេសាទនិងបទល្មើសផ្សេងៗទៀតប្រកបដោយប្រសិទ្ធភាព៖

១.១ពិនិត្យ កែសម្រួល និងពង្រឹងក្រុមការងារល្បាត ដែលមានស្រាប់ ដើម្បីបង្កើនប្រសិទ្ធភាពល្បាត

១.២ ផ្តល់ធនធាននិងឧបរណ៍ សម្ភារៈសម្រាប់ពង្រឹងការងារ ល្បាតប្រកបដោយប្រសិទ្ធភាព

១.៣ រៀបចំនិងអនុវត្តលិខិត បទដ្ឋានគិតិយុត្តិសម្រាប់គ្រប់គ្រងដែនជម្រកសុវត្ថិភាពជលផលក្តាមសេះក្នុងទីតាំងកោះពោធិ៍

១.៤ អនុវត្តសកម្មភាពលុបបំបាត់ ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត (IUU fishing)

<u>គោលបំណងទី២</u>-ធ្វើឱ្យប្រសើរឡើងការពារនិងស្តារទីជម្រកសំខាន់ៗ ដើម្បីធានាបានផលស្តុកធនធានជលផលនៅក្នុងដែនទឹកធម្មជាតិប្រកបដោយប្រសិទ្ធភាព៖

២.១ កំណត់និងទម្លាក់ប្រអប់បេតុងតាមព្រំតំបន់គ្រប់គ្រងទាំងមូល កន្លែងអភិរក្សជលផល ដែនជម្រកសុវត្ថិភាពជលផល កន្លែងអេកូទេសចរណ៍បាតសមុទ្រ និងជម្រកសំខាន់ៗ

២.២ សាងសង់និងទម្លាក់ប្រអប់ឬវត្ថុផ្សេងៗទៀត ដើម្បីបង្កើតជាជម្រកសិប្បនិម្មិតនិងទប់ស្កាត់អួនអូសក្នុងកន្លែងអភិរក្ស ដែនជម្រកសុវត្ថិភាព និងទីតាំងស្មៅសមុទ្រនិងផ្កាថ្មសំខាន់ៗ

២.៣ សិក្សាពីប្រសិទ្ធភាពប្រអប់សិប្បនិម្មិត

២.៤ស្តារទីជម្រកផ្កាថ្ម

<u>គោលបំណងទី៣</u>-បណ្តុះបណ្តាលនិងបង្កើនការយល់ដឹងជាសាធារណៈដល់មន្ត្រីជំនាញ សមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀតអំពីតួនាទីតំបន់គ្រប់គ្រងជលផលតម្លៃប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងជីវចម្រុះជលផល ដើម្បីជំរុញការគ្រប់គ្រងធនធានជលផលឱ្យប្រសើរឡើង៖

៣.១ រៀបចំហេត្ថារចនាសម្ព័ន្ធសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយ

៣.២ ផ្តល់ជំនាញស្រាវជ្រាវនិងគ្រប់គ្រងធនធានជលផលដល់មន្ត្រីពាក់ព័ន្ធនិងសហគមន៍

៣.៣បង្កើនការយល់ដឹងជាសាធារណៈដល់អ្នកពាក់ព័ន្ធឱ្យយល់ដឹងពីអត្ថប្រយោជន៍នៃតំបន់គ្រប់គ្រងជលផល កន្លែងគ្រប់គ្រងជលផលនីមួយៗ ប្រព័ន្ធអេកូឡូស៊ី និងប្រភេទធនធានជលផល ដែលកំពុងរងគ្រោះថ្នាក់

៣.៤ បង្កើតកម្មវិធីអប់រំ ស្តីពីការកាត់បន្ថយការបំពុលបរិស្ថាន

៣.៥ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍

<u>គោលបំណងទី៤</u>-សិក្សាស្រាវជ្រាវនិងតាមដានត្រួតពិនិត្យស្ថានភាពទីជម្រក និងធនធានជលផលសំខាន់ៗ ដើម្បីជួយដល់ការងារការពារនិងអភិរក្សប្រកបដោយប្រសិទ្ធភាព៖

៤.១ ចងក្រងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងទីជម្រកប្រព័ន្ធអេកូឡូស៊ីធនធានជីវចម្រុះជលផល និងស្ថានភាពការគំរាមកំហែង

៤.២ តាមដានវាយតម្លៃប្រព័ន្ធអេកូឡូស៊ីនិងជីវចម្រុះជលផលសំខាន់ៗក្នុងកន្លែងអភិរក្សជលផល និងទីតាំងសំខាន់ដទៃទៀត

៤.៣ សិក្សានិងចងក្រងប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់

៤.៤ សិក្សាវាយតម្លៃពីវដ្តវបន្តពូជនៃក្តាមសេះ

៤.៥ ត្រួតពិនិត្យនិងកំណត់គោលការណ៍ប៉ារ៉ាម៉ែត្រគុណភាពទឹកក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ

<u>គោលបំណងទី៥</u>-ធានាបាននិរន្តរភាពថវិកាក្នុងការគ្រប់គ្រង និងធ្វើឱ្យប្រសើរឡើងនូវមុខរបរចិញ្ចឹមជីវិតរបស់សហគមន៍នេសាទដើម្បីកាត់បន្ថយការដាក់សម្ពាធលើធនធានជលផល៖

៥.១ វាយតម្លៃពីតម្រូវការជម្រើសមុខរបរចិញ្ចឹមជិវិត

៥.២ កម្មវិធីអនុវត្តសាកល្បងនៃជម្រើសមុខរបរចិញ្ចឹមជីវិត

៥.៣ ការស្រាវជ្រាវនិងអនុវត្តពីការយកថ្លៃពីទេសចរឬក្រុមហ៊ុនមុជទឹកដែលចុះមុជមើលធនធានបាតសមុទ្រនិងទស្សនាសត្វផ្សោត

៥.៤ ស្វែងរកដៃគូដើម្បីគាំទ្រគម្រោង

<u>គោលបំណងទី៦</u>- ពង្រឹងយន្តការគ្រប់គ្រងចម្រុះ ដើម្បីធានាបានការគ្រប់គ្រងធនធានជលផលក្នុងតំបន់គ្រប់គ្រងជលផលខេត្តកែបប្រកបដោយប្រសិទ្ធភាពខ្ពស់៖

៦.១ បង្កើតនិងប្រត្តិបត្តិនៃគណៈកម្មការគ្រប់គ្រងថ្នាក់ខេត្តដើម្បីគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប

៦.២ បង្កើតនិងប្រតិបត្តិនៃក្រុមការងារបច្ចេកទេសស្តីពីតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប

៦.៣ រាយការណ៍ពីលទ្ធផល នៃការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលទៅថ្នាក់ជាតិ ដើម្បីទទួលបានការគាំទ្រពីរាជរដ្ឋាភិបាលនិងអង្គការពាក់ព័ន្ធ

៦.៤ រាយការណ៍ពីលទ្ធផលនៃការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលទៅថ្នាក់តំបន់និងអន្តរជាតិ ដើម្បីទទួលបានការគាំទ្រ

៦.៥ ពង្រឹងកិច្ចសហការទ្វេរភាគីរវាងខេត្តកៀងយ៉ាង និងខេត្តកែប ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានជលផលនៃខេត្តទាំងពីរ

## ៥. រចនាសម្ព័ន្ធសម្រាប់ការអនុវត្តសកម្មភាពនិងការទទួលខុសត្រូវ

ការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រ ត្រូវបានប្រើជាសហគ្រប់គ្រង ដែលមានការចូលរួមពីថ្នាក់ ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ព្រមទាំងមានការចូលរួមពីសហគមន៍នេសាទ សហគមន៍ទេសចរណ៍ សង្គមស៊ីវិល និងវិស័យឯកជន។ វិធីសាស្រ្តនេះនឹងជួយឱ្យមានការទទួលខុសត្រូវច្បាស់លាស់ ប្រសិទ្ធភាព និងទទួលបានអន្តរាគមន៍ទាន់ពេលវេលា។ ខាងក្រោមគឺជារចនាសម្ព័ន្ធគ្រប់គ្រង សម្រាប់តំបន់គ្រប់គ្រងជលផលសមុទ្រនៅ ប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប។




## ៦. ថវិកាប៉ាន់ស្មាន

ថវិកាប៉ាន់ស្មានសម្រាប់ការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយខេត្តកែប សម្រាប់រយៈពេល៣ឆ្នាំ មានចំនួនប្រហែល ៧០១៩២០ ដុល្លារអាមេរិក ដែលថវិកានេះអាចនឹងទទួល បានពីថវិកាជាតិដៃគូអភិវឌ្ឍន៍នានាវិស័យឯកជនសប្បុរសជន និងចំណូលផ្សេងៗ។

**តារាងទី៧ ៖ ថវិកាប៉ាន់ស្មានសម្រាប់ការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិនិងកោះទន្សាយ ខេត្តកែប សម្រាប់រយៈពេល៥ឆ្នាំ**

| **គោលបំណង** | **ថវិកា** (**ដុល្លារអាមេរិក**) |
|---|---|
| គោលបំណង១៖ពង្រឹងការអនុវត្តច្បាប់ ដើម្បីទប់ស្កាត់បទល្មើសនេសាទនិងបទល្មើសផ្សេងៗទៀតប្រកបដោយប្រសិទ្ធភាព | **225,220** |
| គោលបំណង២៖ ធ្វើឱ្យប្រសើរឡើងការពារនិងស្តារទីជម្រកសំខាន់ៗ ដើម្បីធានាបានផលស្តុកធនធានជលផលនៅក្នុងដែនទឹកធម្មជាតិប្រកបដោយប្រសិទ្ធភាព | **230,100** |
| គោលបំណង៣៖បណ្តុះបណ្តាលនិងបង្កើនការយល់ដឹងជាសាធារណៈដល់មន្ត្រីជំនាញ សមាជិកសហគមន៍និងអ្នកពាក់ព័ន្ធផ្សេងទៀតអំពីតួនាទីតំបន់គ្រប់គ្រងជលផលតម្លៃប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងជីវចម្រុះជលផល ដើម្បីជំរុញការគ្រប់គ្រងធនធានជលផលឱ្យប្រសើរឡើង | **83,200** |
| គោលបំណង៤៖សិក្សាស្រាវជ្រាវនិងតាមដានត្រួតពិនិត្យស្ថានភាពទីជម្រក និងធនធានជលផលសំខាន់ៗដើម្បីជួយដល់ការងារការពារនិងអភិរក្សប្រកបដោយប្រសិទ្ធភាព | **774,00** |
| គោលបំណង៥៖ធានាបាននិរន្តរភាពថវិកាក្នុងការគ្រប់គ្រង និងធ្វើឱ្យប្រសើរឡើងនូវមុខរបរចិញ្ចឹមជីវិតរបស់សហគមន៍នេសាទដើម្បីកាត់បន្ថយការដាក់សម្ពាធលើធនធានជលផល | **34,600** |
| គោលបំណង៦៖ពង្រឹងយន្តការគ្រប់គ្រងចម្រុះដើម្បីធានាបានការគ្រប់គ្រងធនធានជលផលក្នុងតំបន់គ្រប់គ្រងជលផលខេត្តកែបប្រកបដោយប្រសិទ្ធភាពខ្ពស់ | **51,400** |
| សរុប | **701,920** |

## ៧. ការតាមដាន និងវាយតម្លៃ

តារាងពិន្ទុ METTគឺជាឧបករណ៍មួយដែលបានយកលំនាំតាមឧបករណ៍ដែលបានរៀបចំដោយសម្ព័ន្ធភាពធនាគារពិភពលោកនិងអង្គការ WWF សម្រាប់តំបន់ការពារធម្មជាតិដីគោកក្នុងគោលបំណងជួយអ្នកគ្រប់គ្រងតំបន់ការពារធម្មជាតិសមុទ្រនិងអ្នកពាក់ព័ន្ធនៅមូលដ្ឋានកំណត់ពីវឌ្ឍនភាពរបស់ខ្លួននៅក្នុងដំណើរការគ្រប់គ្រង។នេះជាឧបករណ៍ស្វ័យវាយតម្លៃដ៏ងាយស្រួលនិងខ្លីមួយសម្រាប់ជួយអ្នកគ្រប់គ្រងកំណត់អំពីចំណុចជោគជ័យ និងចំណុចដែលត្រូវកែលម្អភាពខ្វះចន្លោះរបស់ខ្លួន។

ក្របខណ្ឌរបស់គណៈកម្មាធិការតំបន់ការពារពិភពលោក(WCPA) បានផ្អែកលើគំនិតដែលថាការគ្រប់គ្រងតំបន់ការពារធម្មជាតិបានល្អត្រូវធ្វើតាមដំណើរការមួយដែលមានដំណាក់កាលឬមានធាតុផ្សំខុសគ្នាចំនួន៦ ដូចជា១. បរិបទ ២. ការរៀបចំផែនការ ៣. ធាតុចូល ៤. ដំណើរការ ៥. ធាតុចេញ៦. លទ្ធផល។

តារាងពិន្ទុនេះមិនតម្រូវឲ្យមានការប្រមូលព័ត៌មានបន្ថែមហើយការវាយតម្លៃអាចធ្វើឡើងដោយអ្នកពាក់ព័ន្ធសំខាន់ៗឬអ្នកគ្រប់គ្រងដែលពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងទីកន្លែងនោះ។

## ឯកសារយោង


រដ្ឋបាលជលផល (២០១៧)-របាយការណ៍បូកសរុបប្រចាំឆ្នាំរបស់វិស័យជលផល ដែលដាក់ឱ្យប្រើប្រាស់ជារៀងរាល់ឆ្នាំ

រដ្ឋបាលខេត្តកែប (២០១៥)- ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០១៥-២០១៩)។ របាយការណ៍របស់រដ្ឋបាលខេត្តកែប បោះពុម្ពផ្សាយនាខែមីនា ឆ្នាំ២០១៥

Bjorndal, K.A. & Bolten, A.B. 2010, "Hawksbill sea turtles in seagrass pastures: success in a peripheral habitat", *Marine Biology,* vol. 157, no. 1, pp. 135-145.

CBD (2010).Strategic Plan for Biodiversity 2011–2020 and the Aichi Targets.Report of the Tenth Meeting of the Conference of the Parties to the Convention on Biological Diversity. Nagoya, Japan: Convention on Biological Diversity.

Blaber, S. J. M., D. T. Brewer, and J. P. Salini. (1989). “Species composition and biomasses of shes in different habitats of a tropical northern Australian estuary: their occurrence in the adjoining sea and estuarine dependence”. Estuar.Coast. Shelf Sci. 29: 509–531.

Heithaus MR, Dill LM, Marshall GJ, & Buhleier B 2002, "Habitat use and foraging behavior of tiger sharks (*Galeocerdo cuvier*) in a seagrass ecosystem", *Marine Biology,* vol. 140, no. 2, pp. 237-248

Kathiresan, K & Rajendran, N 2005, "Coastal mangrove forests mitigated tsunami", *Estuarine, Coastal and Shelf Science,* vol. 65, no. 3, pp. 601-606.

Krell B, Skopal M & Ferber P 2011, “Koh Rong Samloem and Koh Kon Marine Environmental Assessment”, Marine Conservation Cambodia, Cambodia.

Lugendo, B.R., Nagelkerken, I., Kruitwagen, G., van der Velde, G. & Mgaya, Y.D. 2007, "Relative importance of mangroves as feeding habitats for fishes: a comparison between mangrove habitats with different settings", *Bulletin of Marine Science,* vol. 80, no. 3, pp. 497-512.

Lugendo, B. R., A. Pronker, I. Cornelissen, A. de Groene, I. Nagelkerken, M. Dorenbosch, G. van der Velde, and Y. D. Mgaya. 2005. Habitat utilization by juveniles of commercially important sh species in Chwaka Bay, Zanzibar, Tanzania. Aquat.Living Resour. 18: 149–158.

Londono, L.M. & Johnston, R.J. 2012, "Enhancing the reliability of benefit transfer over heterogeneous sites: A meta-analysis of international coral reef values", Ecological Economics, vol. 78, pp. 80.

MCC. (2016). Stage I zoning proposal for the Kep Archipelago. The research conducted to support the establishment of Marine Fisheries Management in Kep Province

Nelson, V. (1999). Draft Coastal Profile: Volume I, II: The Coastal Zone of Cambodia-Current status and Threats. MoE/DANIDA Coastal Zone Management Project, Phnom Penh, Cambodia.

Vivol, O. (2017). Reasearch report on Fisheries Resources and Fishing around Koh Po, Kep Province. Report in Khmer.

Vibol, O. Nam, S. Puy, L. Sereywath, P. (2010). Seagrass Diversity and distribution in Kampot. Paper published at International Journal of Environment and Rural Development (2010)

SCS (2004). Seagrass in South China Sea under the project of Reversing Environmental Degradation Trends in the South China Sea and Gulf of Thailand.

Taquet, C., Taquet, M., Dempster, T., Soria, M., Ciccione, S., Roos, D. & Dagorn, L. 2006, "Foraging of the green sea turtle Chelonia mydas on seagrass beds at Mayotte Island (Indian Ocean), determined by acoustic transmitters", *Marine Ecology Progress Series,* vol. 306, pp. 295-302.

## ៨. ឧបសម្ព័ន្ធ

### ឧបសម្ព័ន្ធ ១៖ តារាងសកម្មភាពលំអិត សូចនាករ ពេលវេលា ស្ថាប័នអនុវត្ត និងថវិកា

សម្គាល់៖Hអាទិភាពខ្ពស់ M អាទិភាពមធ្យម L អាទិភាពទាប

| សកម្មភាពការងារ | សកម្មភាព | លទ្ធផលសូចនាករ/ | អង្គភាពអនុវត្ត | ពេលវេលា | ថវិកា | អទិភាព |
|---|---|---|---|---|---|---|
| គោលបំណងទី១៖ពង្រឹងការអនុវត្តច្បាប់ ដើម្បីទប់ស្កាត់បទល្មើសនេសាទនិងបទល្មើសផ្សេងៗទៀតប្រកបដោយប្រសិទ្ធភាព | | | | | | |
| ១.១ពិនិត្យ កែសម្រួល និងពង្រឹងក្រុមការងារល្បាត ដែលមានស្រាប់ ដើម្បីបង្កើនប្រសិទ្ធភាពល្បាត | ១.១.១ រៀបចំប្រជុំTWG – Kep MFMA ដើម្បីពិនិត្យនិងកែសម្រួលបង្កើតក្រុមល្បាត | របាយការណ៍កិច្ចប្រជុំដែលបានឯកភាពពីប្រធាន TWG-Kep MFMA | DFC, FiAC-Kep និងរដ្ឋបាលខេត្តកែប | ត្រីមាសទី១ ២០១៩ | 800 | H |
| | ១.១.២ រៀបចំផែនការ និងអនុវត្តសកម្មភាពល្បាតរបស់ក្រុមល្បាត | ផែនការល្បាតប្រចាំខែ ត្រូវបានរៀបចំនិងអនុម័ត ដោយប្រធាន TWG-Kep MFMA | ក្រុមការងារល្បាត | ២០១៩- ២០២១ | 720 | H |
| ១.២ ផ្តល់ធនធាននិងឧបករណ៍ សម្ភារៈសម្រាប់ពង្រឹងការងារល្បាតប្រកបដោយប្រសិទ្ធភាព | ១.២.១ ប្រជុំពិគ្រោះយោបល់ជារៀងរាល់ឆ្នាំ ដើម្បីពិភាក្សាពីតម្រូវការឧបករណ៍និងសម្ភារៈ សម្រាប់ការងារល្បាត | របាយការណ៍កិច្ចប្រជុំដែលបានឯកភាពពីប្រធាន TWG-Kep MFMA | DFC, FiAC-Kep និងរដ្ឋបាលខេត្តកែប | ២០១៩- ២០២១ | 4,800 | H |
| | ១.២.២ ស្វែងរកដៃគូគាំទ្រដើម្បីបំពាក់សម្ភារៈល្បាត | កាណូតល្បាតចំនួន០១គ្រឿង អាវពោង ម៉ាស៊ីនថត GPS...(ថវិកាពីរដ្ឋាភិបាល EU, MCC, SEAFDEC, IUCN...) | DFC, FiAC-Kep និងរដ្ឋបាលខេត្តកែប | ២០១៩-២០២១ | 100,000 | H & M |

| | | | | | | |
|---|---|---|---|---|---|---|
| | ១.២.៣ ចែកឧបករណ៍សម្ភារៈដល់ក្រុមល្បាត | បច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌ | TWG-Kep MFMA | ២០១៩- ២០២១ | 0 | H |
| | ១.២.៤រៀបចំស្នាក់ការល្បាតប្រចាំនៅលើកោះអាចម៍សេះ | ស្នាក់ការល្បាតត្រូវបានរៀបចំសម្រាប់ការងារល្បាតនិងសិក្សាស្រាវជ្រាវ | DFC, FiAC-Kep, MCC និងរដ្ឋបាលខេត្តកែប | ត្រីមាសទី២ ២០២១ | 2,500 | H |
| ១.៣ រៀបចំនិងអនុវត្តលិខិតបទដ្ឋានគតិយុត្តិសម្រាប់គ្រប់គ្រងដែនជម្រកសុវត្ថិភាពជលផលក្តាមសេះក្នុងទីតាំងកោះពោធិ៍ | ១.៣.១ រៀបចំប្រជុំពិភាក្សាដើម្បីចេញគោលការណ៍ក្នុងការគ្រប់គ្រងដែនជម្រកក្នុងរដូវហាមឃាត់ចាប់ពីខែ០១ឧសភា ដល់៣១កក្កដា | គោលការណ៍ដែលបានអនុម័តដោយប្រធាន TWG-Kep MFMA | DFC, FiAC-Kep និងរដ្ឋបាលខេត្តកែប | ត្រីមាសទី២ ឆ្នាំ២០១៩-២០២២ | 800 | H |
| | ១.៣.២ រៀបចំនិងស្លាកសញ្ញាហាមឃាត់ ក្នុងរដូវហាមឃាត់នេសាទ | យ៉ាងហោចណាស់ ពោងនិងស្លាកសញ្ញាចំនួន៥០ត្រូវបានតម្លើង | ក្រុមការងារល្បាត | ត្រីមាសទី២ ឆ្នាំ២០១៩ | 25,000 | H |
| | ១.៣.៣ បោះទីតាំងជាប្រចាំលើកោះពោធិ៍និងចុះអន្តរគមន៍ជាបន្ទាន់ប្រសិនមានសកម្មភាពដែលត្រូវហាមឃាត់ក្នុងទីតាំងដែនដែនជម្រកសុវត្ថិភាពជលផល | របាយការណ៍ពីសកម្មភាពអន្តរាគមន៍និងបទល្មើស | ក្រុមការងារល្បាត | ខែ១ឧសភា ដល់៣១កក្កដា (២០១៩-២០២៣) | ប្រើប្រាស់ថវិកាក្នុងសកម្មភាព ១.៤ | H |
| ១.៤ អនុវត្តសកម្មភាពលុបបំបាត់ការនេសាទខុសច្បាប់គ្មានរបាយការណ៍ | ១.៤.១អនុវត្តសកម្មភាពបង្ក្រាបបទល្មើសនេសាទជាប្រចាំ | ចំនួនសកម្មភាពបង្ក្រាប ៧ដង/ខែ | ក្រុមការងារល្បាត | ២០១៩- ២០២៣ | 65,400 | |
| | ១.៤.២ ឃាត់ចាប់និងកសាង | សំណុំរឿងជាក់ស្តែង | ក្រុមការងារល្បាត | ២០១៩- ២០២៣ | 5,000 | |

| | | | | | | |
|---|---|---|---|---|---|---|
| និងគ្មានការអនុញ្ញាត (IUU fishing) | សំណុំរឿងតាមនិតិវិធី | | | | | |
| | ១.៤.៣ធ្វើបច្ចុប្បន្នភាពទិន្នន័យទុកនេសាទ | ចំនួនរបាយការណ៍ដែលជាតម្រូវការរបស់ FiA | FiAC-Kep | តាមការចាំបាច់ | 5,000 | |
| | ១.៤.៤ប្រជុំក្រុមការងារ TWG-Kep MFMA ដើម្បីពិនិត្យនិងកែលម្អសកម្មភាពល្បាត | របាយការណ៍ប្រជុំប្រចាំត្រីមាស | DFC, FiAC-Kep និងរដ្ឋបាលខេត្តកែប | ២០១៩- ២០២២ | 15200 | |
| **គោលបំណងទី២៖ធ្វើឱ្យប្រសើរឡើងនូវការការពារនិងស្តារទីជម្រកសំខាន់ៗ ដើម្បីធានាបានផលស្តុកធនធានជលផលនៅក្នុងដែនទឹកធម្មជាតិប្រកបដោយប្រសិទ្ធភាព** | | | | | | |
| ២.១ កំណត់និងទម្លាក់ប្រអប់បេតុងតាមព្រំតំបន់គ្រប់គ្រងទាំងមូល កន្លែងអភិរក្សជលផល ដែនជម្រកសុវត្ថិភាពជលផល កន្លែងអេកូទេសចរណ៍បាតសមុទ្រ និងជម្រកសំខាន់ៗ | ២.១.១ ប្រជុំក្រុមការងារ TWGKepMFMA ដើម្បីកំណត់ទីតាំងទម្លាក់ប្រអប់បេតុងឬពោង (ប្រើផែនទីដែលភ្ជាប់នឹងប្រកាស) | ផែនទីកន្លែងគ្រប់គ្រងសំខាន់ ទីតាំង និងចំនួនប្រអប់ឬពោងត្រូវបានឯកភាពដោយសមាជិកTWG-Kep MFMA | DFC, FiAC-Kep រដ្ឋបាលខេត្តកែប និង MCC | ត្រីមាសទី២ ឆ្នាំ ២០១៩ | 800 | |
| | ២.១.២ សិក្សាពីប្រភេទប្រអប់បេតុងដែលមានប្រសិទ្ធភាពខ្ពស់ | របាយការណ៍វាយតម្លៃប្រសិទ្ធភាពប្រអប់បេតុង | - DFC, FiAC-Kep និងMCC | ត្រីមាសទី៣ ២០២០ | 0 | ជួយដោយ FAO |
| | ២.១.៣សាងសង់និងទម្លាក់បេតុងប្រអប់និងនៅតាមទីតាំងដែលបានកំណត់ | – ៧០ប្រអប់ត្រូវបានទម្លាក់តាមព្រំកន្លែងអភិរក្ស<br>– ៥០ប្រអប់ ត្រូវបានទម្លាក់តាមព្រំដែនជម្រកសុវត្ថិភាពជលផល<br>–២០០ប្រអប់ ត្រូវបានទម្លាក់នៅតាមព្រំកន្លែងសំខាន់ៗផ្សេងៗទៀត | - DFC, FiAC-Kep និងMCC | ២០១៩-២០២២ | 96,000 | M & H |

| | | | | | | |
|---|---|---|---|---|---|---|
| ២.២ សាងសង់និងទម្លាក់ប្រអប់ ឬវត្ថុផ្សេងៗទៀត ដើម្បីបង្កើតជាជម្រកសិប្បនិម្មិតនិងទប់ស្កាត់អួនអូសក្នុងកន្លែងអភិរក្ស ដែនជម្រកសុវត្ថិភាព និងទីតាំងស្មៅសមុទ្រនិងផ្កាថ្មសំខាន់ៗ | ២.២.១ ប្រជុំជ្រើសរើសទីតាំង ទំលាក់និងចំនួនប្រអប់បេតុង | របាយការណ៍ប្រជុំ និងផែនទីទីតាំង | DFC, FiAC-Kep រដ្ឋបាលខេត្តកែប និង MCC | ត្រីមាសទី២ ២០២០ | 0 | ប្រើថវិកាក្នុង២១.១. |
| | ២.២.២ សិក្សាពីប្រសិទ្ធភាពនៃប្រអប់សិប្បនិម្មិត | របាយការណ៍វាយតម្លៃ | - DFC, FiAC-Kep, MCC & FAO | ត្រីមាសទី៣ ២០២០ | 0 | ជួយដោយ FAO |
| | ២.២.៣ សាងសង់និងទម្លាក់ប្រអប់បេតុងឬវត្ថុផ្សេងៗទៀត ដើម្បីបង្កើតជាជម្រកសិប្បនិម្មិត និងទប់ស្កាត់អួនអូសគ្រប់ប្រភេទ | - ១០០ប្រអប់ត្រូវបានទម្លាក់ក្នុងកន្លែងអភិរក្សជលផល<br>- ១០០ប្រអប់ត្រូវបានទម្លាក់ក្នុងដែនជម្រកសុវត្ថិភាពជលផល<br>- ២០០ប្រអប់ត្រូវបានទម្លាក់នៅកន្លែងសំខាន់ផ្សេងៗទៀត | - នាយកដ្ឋានអភិរក្សជលផល<br>- ខណ្ឌរដ្ឋបាលជលផល<br>- អង្គការសង្គមស៊ីវិល<br>- សហគមន៍នេសាទ | ២០១៩-២០២២ | 120,000 | H |
| ២.៣ សិក្សាពីប្រសិទ្ធភាពប្រអប់សិប្បនិម្មិត | ២.៣.១ ប្រជុំជ្រើសរើសប្រភេទដែលជាសូចនាករសម្រាប់វាយតម្លៃ រួមទាំងក្តាមសេះ | របាយការណ៍បច្ចេកទេស | - DFC, Kep FiA, MCC | ត្រីមាសទី៤ ២០២០ | 0 | |
| | ២.៣.២ សិក្សាពីប្រសិទ្ធភាពនៃប្រអប់សិប្បនិម្មិតលើជីវចម្រុះ | របាយការណ៍បច្ចេកទេស | - DFC, Kep FiA, MCC | ត្រីមាសទី២ ២០២០ | 6,000 | M |
| | ២.៣.៣ | របាយការណ៍បច្ចេកទេស | DFC, Kep FiA, MCC | ត្រីមាសទី១រៀងរាល់ឆ្នាំ | 2,000 | M |

| | | | | | | |
|---|---|---|---|---|---|---|
| | សិក្សាពីប្រសិទ្ធភាពនៃប្រអប់សិប្បនិម្មិតលើបទល្មើសនេសាទ | | | ចាប់ពីឆ្នាំ២០២០ | | |
| ២.៤ស្តារទីជម្រកផ្កាថ្ម | ២.៤.១ ជ្រើសរើសទីតាំងដើម្បីស្តារទីជម្រកផ្កាថ្ម | ឯកភាពផែនទីដែលត្រូវស្តារ | DFC, Kep FiA, MCC TWG-Kep MFMA | ត្រីមាសទី២ ២០១៩ និង២០២១ | 800 | M |
| | ២.៤.២ សិក្សាពីបទពិសោធន៍ផ្សេងៗពីវិធីសាស្ត្រដាំផ្កាថ្ម | របាយការណ៍បច្ចេកទេស | DFC, Kep FiA, MCC | ត្រីមាសទី២ ឆ្នាំ២០១៩ | 1,000 | M |
| | ២.៤.៣ ដាំផ្កាថ្មនៅលើទីតាំងដែលបានកំណត់ | យ៉ាងហោចណាស់រងដាំផ្កាថ្មចំនួន៣០ ត្រូវបានដាក់ដាំ | DFC, Kep FiA, MCC | ត្រីមាសទី២ ២០២០ និង២០២២ | 2,500 | L |
| | ២.៤.៤ ចូលរួមទិវាសមុទ្រពិភពលោកដោយសំអាតឆ្នេរនិងតំបន់ផ្កាថ្ម | សកម្មភាពនៃពិធី | TWG-Kep MFMA | រៀងរាល់ខែមិថុនា ២០១៩- ២០២២ | 1,000 | M |
| គោលបំណងទី៣៖បណ្តុះបណ្តាលនិងបង្កើនការយល់ដឹងជាសាធារណៈដល់មន្ត្រីជំនាញ សមាជិកសហគមន៍និងអ្នកពាក់ព័ន្ធផ្សេងទៀតអំពីតួនាទីតំបន់គ្រប់គ្រងជលផលតម្លៃប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងជីវចម្រុះជលផល ដើម្បីជំរុញការគ្រប់គ្រងធនធានជលផលឱ្យប្រសើរឡើង | | | | | | |
| ៣.១ រៀបចំហេត្ថារចនាសម្ព័ន្ធសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយ | ៣.១.១ សកម្មភាពដូចក្នុង ១.២.៤ | ស្លាក់ការដែលមានស្រាប់លើកោះអាចម៍សេះ ត្រូវបានលើកស្លាកនិងកែលម្អ | TWG-Kep MFMA | ត្រីមាសទី២ ឆ្នាំ២០២០ | 0 | ប្រើថវិកាក្នុង ១ ៣.២. |
| | ៣.១.២ បំពាក់សម្ភារៈសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយ | បញ្ជីសារពើភ័ណ្ឌសម្ភារៈស្រាវជ្រាវនិងផ្សព្វផ្សាយ | DFC, Kep FiA, MCC | ត្រីមាសទី២ ឆ្នាំ២០១៩-២០២០ | 5,000 | M |
| ៣.២ ផ្តល់ជំនាញស្រាវជ្រាវនិងគ្រប់គ្រងធនធានជលផលដល់ | ៣.២.១ វាយតម្លៃពីជំនាញដែលជាតម្រូវការដល់មន្ត្រីជំនាញនិង | របាយការណ៍វាយតម្លៃ | DFC, Kep FiA, MCC | ត្រីមាសទី២ ឆ្នាំ២០២០ | 800 | H |

| | | | | | | |
|---|---|---|---|---|---|---|
| មន្ត្រីពាក់ព័ន្ធនិងសហគមន៍ | សមាជិកសហគមន៍ | | | | | |
| | ៣.២.២ ផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីពីជំនាញមុជទឹក | យ៉ាងហោចណាស់ វគ្គបណ្តុះបណ្តាលចំនួន០២ ត្រូវបានរៀបចំឡើង | DFC, Kep FiA, MCC | ត្រីមាសទី២ ឆ្នាំ២០២០ និងត្រីមាសទី១ ឆ្នាំ២០២១ | 10,000 | H |
| | ៣.២.៣ វគ្គបណ្តុះបណ្តាលស្តីពីការតាមដានសុខភាព របាយការណ៍ផ្កាថ្មនិងស្មៅសមុទ្រ ជីវចម្រុះ និងតាមដានគុណភាពទឹក | យ៉ាងហោចណាស់ វគ្គបណ្តុះបណ្តាលចំនួន០២ ត្រូវបានរៀបចំឡើង | DFC, Kep FiA, MCC | ត្រីមាសទី២ ឆ្នាំ២០២០ និងត្រីមាសទី១ ឆ្នាំ២០២១ | 0 | អាចរៀបចំជាមួយ ៣២.២. |
| | ៣.២.៤ វគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃផលស្តុកក្តាមសេះ ក្នុងដែនជម្រកសុវត្ថិភាពជលផលក្តាមសេះ ការវិវត្តកន្សោមពងរដូវទម្លាក់កូន ឧបករណ៍នេសាទក្តាមសេះ និងស្ថានភាពផលចាប់ | យ៉ាងហោចណាស់ វគ្គបណ្តុះបណ្តាលចំនួន០១ ត្រូវបានរៀបចំឡើង | អ្នកជំនាញ | ត្រីមាសទី៤ ឆ្នាំ២០២០ | 2,500 | H |
| | ៣.២.៥ វគ្គបណ្តុះបណ្តាលស្តីពី SMART ដល់មន្ត្រីល្បាតនិងសមាជិកសហគមន៍ | យ៉ាងហោចណាស់ វគ្គបណ្តុះបណ្តាលចំនួន០២ ត្រូវបានរៀបចំឡើង | អ្នកជំនាញ | ត្រីមាសទី២ ឆ្នាំ២០២០ និងត្រីមាសទី១ ឆ្នាំ២០២១ | 2,500 | M |
| | ៣.២.៦ វគ្គបណ្តុះបណ្តាលដល់សមាជិកសហគមន៍ក្នុងការកត់ | យ៉ាងហោចណាស់ វគ្គបណ្តុះបណ្តាលចំនួន០២ | DFC, Kep FiA, MCC | ត្រីមាសទី៣ ឆ្នាំ២០២០ | 1,600 | M |

| | | | | | | |
|---|---|---|---|---|---|---|
| | ត្រាផលចាប់និងប្រភេទជលផល | ត្រូវបានរៀបចំឡើងអ្នកនេសាទចំនួន៣០រូប | | និងត្រីមាសទី១ ឆ្នាំ២០២១ | | |
| ៣.៣បង្កើនការយល់ដឹងជាសាធារណៈដល់អ្នកពាក់ព័ន្ធឱ្យយល់ដឹងពីអត្ថប្រយោជន៍នៃតំបន់គ្រប់គ្រងជលផល កន្លែងគ្រប់គ្រងជលផលនីមួយៗ ប្រព័ន្ធអេកូឡូស៊ី និងប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ | ៣.៣.១ វាយតម្លៃពីតម្រូវការនិងវិធីសាស្ត្រផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាព | របាយការណ៍ប្រជុំវាយតម្លៃ | TWG-Kep MFMA | ត្រីមាសទី២ ឆ្នាំ២០២០ | 800 | H |
| | ៣.៣.២ រៀបចំនិងបោះពុម្ពឯកសារផ្សព្វផ្សាយ | យ៉ាងហោចណាស់ ផ្ទាំងរូបភាព ខិត្តប័ណ្ណ និងឯកសារលិខិតបទដ្ឋានពាក់ព័ន្ធចំនួន៣០០០ ត្រូវបានបោះពុម្ពសម្រាប់ផ្សព្វផ្សាយ | DFC, Kep FiA/DAFF | ត្រីមាសទី១និង២ នៃឆ្នាំ២០១៩-២០២១ | ៣០,០០០ | H |
| | ៣.៣.៣ ចុះផ្សព្វផ្សាយផ្ទាល់ដល់ភូមិអ្នកនេសាទ | ២០ ប្រជុំផ្សព្វផ្សាយជាមួយអ្នកនេសាទ និងអាជ្ញាធរមូលដ្ឋានចំនួន១០០០នាក់ | Kep FiA | ត្រីមាសទី១និង២ នៃឆ្នាំ២០១៩-២០២២ | 20,000 | H |
| | ៣.៣.៤ ផ្សព្វផ្សាយតាមវិទ្យុខេត្ត | ៥០ ដង | រដ្ឋបាលខេត្តកែប | ២០១៩-២០២២ | 1000 | H |
| | ៣.៣.៥ សាងសង់ផ្ទាំងប៉ាណូនៅតាមផែឡើងត្រីនិងទីតាំងសំខាន់ៗ | យ៉ាងហោចណាស់ ផ្ទាំងប៉ាណូចំនួន០៣ ត្រូវបានតម្លើង | Kep FiA និងអាជ្ញាធរ | ត្រីមាសទី២ ២០១៩ និងត្រីមាសទី១ ២០២០ | 4,500 | M |
| ៣.៤ បង្កើតកម្មវិធីអប់រំស្តីពីការបំពុលបន្ថយការកាត់បរិស្ថាន | ៣.៤.១រៀបចំនិងបោះពុម្ពឯកសារផ្សព្វផ្សាយពាក់ព័ន្ធនឹងការបំពុលបរិស្ថាន | យ៉ាងហោចណាស់ ផ្ទាំងរូបភាព ខិត្តប័ណ្ណ និងឯកសារលិខិតបទដ្ឋានពាក់ព័ន្ធ | DFC, Kep FiA/DAFF និងមន្ទីរបរិស្ថានខេត្ត | ត្រីមាសទី១និង២ នៃឆ្នាំ២០១៩-២០២១ | 1,000 | M |

| | | | | | | |
|---|---|---|---|---|---|---|
| | | ចំនួន១០០០ ត្រូវបានបោះពុម្ពសម្រាប់ផ្សព្វផ្សាយ | | | | |
| | ៣.៤.២ ចុះផ្សព្វផ្សាយផ្ទាល់ដល់ភូមិអ្នកនេសាទនិងកន្លែងឡើងត្រី | ២០ ប្រជុំផ្សព្វផ្សាយ ជាមួយអ្នកនេសាទ និងអាជ្ញាធរមូលដ្ឋានចំនួន១០០០នាក់ | DFC, Kep FiA/DAFF និងមន្ទីរបរិស្ថានខេត្ត | ត្រីមាសទី១និង២ នៃឆ្នាំ២០១៩-២០២១ | 0 | ប្រើក្នុងសកម្មភាព ៣.៣.៣ |
| ៣.៥ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | ៣.៥.១ ទស្សនកិច្ចសិក្សាទៅកាន់តំបន់គ្រប់គ្រងជលផលកោះរ៉ុង ខេត្តព្រះសីហនុ | ទស្សនកិច្ចចំនួន០១ លើកត្រូវបារៀបចំ | DFC, Kep FiA និងរដ្ឋបាលខេត្តកែប | ២០២០ | 3,500 | L |
| **គោលបំណងទី៤៖ សិក្សាស្រាវជ្រាវនិងតាមដានត្រួតពិនិត្យស្ថានភាពទីជម្រក និងធនធានជលផលសំខាន់ៗដើម្បីជួយដល់ការងារការពារនិងអភិរក្សប្រកបដោយប្រសិទ្ធភាព** | | | | | | |
| ៤.១ ចងក្រងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងទីជម្រក ប្រព័ន្ធអេកូឡូស៊ី ធនធានជីវចម្រុះជលផល និងស្ថានភាពការគំរាមកំហែង | ៤.១.១ ប្រជុំពិភាក្សាក្រុមការងារបច្ចេកទេសដើម្បីឯកភាពលើចំណុចគោលសំខាន់ | ចំណុចគោលសំខាន់ៗ ត្រូវបានឯកភាព | TWG-Kep MFMA | ត្រីមាសទី៣ ២០២០ | 800 | H |
| | ៤.២.១ ប្រមូលនិងចងក្រងឯកសារបច្ចេកទេស | របាយការណ៍បច្ចេកទេស | - ទីប្រឹក្សា | ត្រីមាសទី៤ ឆ្នាំ២០២០ | 2,500 | M |
| ៤.២ តាមដានវាយតម្លៃប្រព័ន្ធអេកូឡូស៊ីនិងជីវចម្រុះជលផលសំខាន់ៗក្នុងកន្លែងអភិរក្សជលផលនិងទីតាំងសំខាន់ដទៃទៀត | ៤.២.១ ប្រជុំពិភាក្សាក្រុមការងារបច្ចេកទេសដើម្បីឯកភាពលើទីតាំងវាយតម្លៃប្រព័ន្ធអេកូឡូស៊ី និងប្រភេទធនធានជលផលដែលជាសូចនាករសំខាន់ៗ | របាយការណ៍ប្រជុំដែលមានការឯកភាពលើទីតាំងនិងប្រភេទដែលជាសូចនាករ | TWG-Kep MFMA | ត្រីមាសទី៤ ២០២០ | 800 | H |
| | ៤.២.២ ចុះសិក្សាពីស្ថានភាព | របាយការណ៍បច្ចេកទេស | - DFC, Kep | ត្រីមាសទី១ | 5,000 | H |

| | | | | | | |
|---|---|---|---|---|---|---|
| | ប្រព័ន្ធអេកូឡូស៊ីនិងធនធានជលផលក្នុងកន្លែងអភិរក្សជលផល | | FiA/DAFFនិង MCC | ឆ្នាំ២០២០ និងត្រីមាសទី៤ ២០២២ | | |
| | ៤.២.៣ចុះសិក្សាពីស្ថានភាពប្រព័ន្ធអេកូឡូស៊ីផលស្កុកក្ដាមសេះ និងប្រភេទសំខាន់ៗផ្សេងទៀត ក្នុងដែនជម្រកសុវត្ថិភាពជលផល | របាយការណ៍បច្ចេកទេស | - DFC, Kep FiA/DAFFនិង MCC | ត្រីមាសទី១ ឆ្នាំ២០២០ និងត្រីមាសទី៤ ២០២២ | 5,000 | H |
| | ៤.២.៤ សិក្សាពីផលចាប់ប្រភេទសំខាន់ៗ ជាពិសេសក្ដាមសេះ ត្រីកាកឹម បង្គា ពពួកគ្រំ-ងាវ និងប្រភេទផ្សេងៗទៀតនៅតាមទីផ្សារនិងកន្លែងឡើងត្រី | របាយការណ៍បច្ចេកទេស | - DFC, Kep FiA/DAFFនិង MCC | ត្រីមាសទី១ ឆ្នាំ២០២០ និងត្រីមាសទី៤ ២០២២ | 3,000 | H |
| ៤.៣សិក្សានិងចងក្រងប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ | ៤.៣.១ ប្រជុំក្រុមការងារបច្ចេកទេសដើម្បីកំណត់ប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ | របាយការណ៍ប្រជុំ | TWG-Kep MFMA | ត្រីមាសទី៤ ២០២០ | 0 | ៥.២.១ |
| | ៤.៣.២ តាមដាននិងកត់ត្រាជាប្រចាំប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ជាពិសេសផ្សោតសមុទ្រ អណ្ដើក | របាយការណ៍បច្ចេកទេស | - DFC, Kep FiA/DAFFនិង MCC | ២០២០-២០២២ | 50,000 | M |

| | | | | | | |
|---|---|---|---|---|---|---|
| | សមុទ្រ សេះសមុទ្រ ជ្រូកទឹក ត្រីយក្ស។ល។ | | | | | |
| ៤.៤ សិក្សាវាយតម្លៃពីរដូវបន្តពូជនៃក្តាមសេះ | ៤.៤.១ សិក្សាវាយតម្លៃពីការវិវត្តកន្សោមពងនិងការញាស់របស់ក្តាមសេះ | របាយការណ៍បច្ចេកទេស | - DFC, Kep FiA/DAFFនិង MCC | ត្រីមាសទី២ ២០២០ ដល់ត្រីមាសទី២ ២០២០ | 6,000 | M |
| | ៤.៤.២ កែសម្រួលលិខិតបទដ្ឋានច្បាប់សម្រាប់គ្រប់គ្រងក្តាមសេះប្រកបដោយប្រសិទ្ធភាព | លិខិតបទដ្ឋានច្បាប់ | TWG-Kep MFMA និង PMC-Kep MFMA | ត្រីមាសទី៣ ២០២០ | 800 | H |
| | ៤.៤.៣ បង្កើតយុទ្ធសាស្ត្រគ្រប់គ្រងក្តាមសេះ | ផែនការយុទ្ធសាស្ត្រ | TWG-Kep MFMA | ត្រីមាសទី៤ ២០២០ | 3,500 | M |
| ៤.៥ ត្រួតពិនិត្យនិងកំណត់គោលការណ៍ប៉ារ៉ាម៉ែត្រគុណភាពទឹកក្នុងតំបន់គ្រប់គ្រងផលផលសមុទ្រ | ៤.៥.១ ប្រជុំក្រុមការងារបច្ចេកទេសជាមួយមន្ត្រីជំនាញបរិស្ថាន ដើម្បីកំណត់ប៉ារ៉ាមែត្រទឹកសម្រាប់ការវាស់វែង | ប៉ារ៉ាមែត្រទឹកត្រូវបានកំណត់ | TWG-Kep MFMA និង មន្ទីរបរិស្ថាន | ត្រីមាសទី៤ ២០២០ | 0 | ៥១.២. |
| **គោលបំណងទី៥៖ ធានាបាននិរន្តរភាពថវិកាក្នុងការគ្រប់គ្រង និងធ្វើឱ្យប្រសើរឡើងនូវមុខរបរចិញ្ចឹមជីវិតរបស់សហគមន៍នេសាទដើម្បីកាត់បន្ថយការដាក់សម្ពាធលើធនធានជលផល** | | | | | | |
| ៥.១ វាយតម្លៃពីតម្រូវការជម្រើសមុខរបរចិញ្ចឹមជិវិត | ៥.១.១ចុះវាយតម្លៃជម្រើសមុខរបរដែលមានសក្តានុពលដល់ប្រជានេសាទ | របាយការណ៍បច្ចេកទេសស្តីពីមុខរបរ | - ទីប្រឹក្សាបច្ចេកទេស | ត្រីមាសទី១ ឆ្នាំ២០២០ | 3,500 | M |
| ៥.២ កម្មវិធីអនុវត្តសាកល្បងនៃជម្រើសមុខរបរចិញ្ចឹមជីវិត | ៥.២.១ កំណត់ទីតាំងនិងក្រុមគោលដៅ | - ទីតាំងចំនួន៣ ត្រូវបានកំណត់<br>- ក្រុមគោលដៅចំនួន៣ត្រូវ | DFC, Kep FiA និងរដ្ឋបាលខេត្តកែប | ត្រីមាសទី២ ឆ្នាំ២០២០ | 0 | M |

| | | | | | | |
|---|---|---|---|---|---|---|
| | | បានជ្រើសរើស | | | | |
| | ៥.២.២ អនុវត្តគម្រោងសាកល្បងជាមួយក្រុមគោលដៅ | - ក្រុមគោលដៅចំនួន៣ត្រូវបានផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេស<br>- ត្រួតពិនិត្យដំណើរការអនុវត្ត | DFC, Kep FiA និងរដ្ឋបាលខេត្តកែប | ២០២០-២០២២ | 20,000 | M |
| | ៥.៣.២ តាមដាននិងវាយតម្លៃគម្រោងសាកល្បង | របាយការណ៍វាយតម្លៃគម្រោងសាកល្បង | DFC, Kep FiA និងរដ្ឋបាលខេត្តកែប | ត្រីមាសទី២ ឆ្នាំ២០២១និងត្រីមាសទី៣ ឆ្នាំ២០២៣ | 7,000 | M |
| ៥.៣ ការស្រាវជ្រាវនិងអនុវត្តពីការយកថ្លៃពីទេសចរណ៍ ឬក្រុមហ៊ុនមុជទឹកដែលចុះមុជមើលធនធានបាតសមុទ្រ និងទស្សនាសត្វផ្សោត | ៥.៣.១ ប្រជុំពិភាក្សាជ្រើសរើសទីតាំងដែលមានសក្តានុពលអេកូឡូស៊ីទេសចរណ៍បាតសមុទ្រ | យ៉ាងហោចណាស់តំបន់អេកូទេសចរណ៍បាតសមុទ្រចំនួន០២កន្លែងត្រូវបានជ្រើសរើស | TWG-Kep MFMA | ត្រីមាសទី២ ២០២០ | 800 | H |
| | ៥.៣.២ ផ្សព្វផ្សាយពីសក្តានុពលនៃធនធានជលផលបាតសមុទ្រនិងផ្សោតដល់ក្រុមហ៊ុនទេសចរណ៍ដើម្បីចូលមកកំសាន្ត | - កិច្ចប្រជុំផ្សព្វផ្សាយដល់ក្រុមហ៊ុនទេសចរណ៍និងវិស័យឯកជនចំនួន០១ដងត្រូវបារៀបចំ<br>- ខិតប័ណ្ណផ្សព្វផ្សាយពីសក្តានុពលធនធានជលផលចំនួន២០០០ ត្រូវបានរៀបចំនិងផ្សព្វផ្សាយ | - DFC, Kep FiA និងរដ្ឋបាលខេត្តកែប<br>- មន្ទីរទេសចរណ៍ខេត្ត | ត្រីមាសទី១ ឆ្នាំ២០២០ | 2,500 | H |
| | ៥.៣.៣ ប្រជុំពិភាក្សាជាមួយ | - របាយការណ៍កិច្ចប្រជុំ | - DFC, Kep FiAនិង | ត្រីមាសទី១ | 0 | ថវិកាប្រើ |

| | | | | | | |
|---|---|---|---|---|---|---|
| | ក្រុមហ៊ុនទេសចរណ៍ ផ្នែកឯកជន និងមន្ទីរទេសចរណ៍ខេត្តពីការកំណត់តម្លៃវិភាគទាន ការគ្រប់គ្រង និងការបែងចែកថវិកា | | រដ្ឋបាលខេត្តកែប<br>- មន្ទីរទេសចរណ៍ខេត្ត | ឆ្នាំ២០២០ | | ក្នុង ៤.៣.២ |
| | ៥.៣.៤ អនុវត្តការប្រមូល ការគ្រប់គ្រងនិងប្រើប្រាស់ថវិកាដែលប្រមូលបាន ប្រកបដោយតម្លាភាព | - ក្រុមការងារគ្រប់គ្រងថវិកាត្រូវបានបង្កើត<br>- ចរន្តថវិកា | - DFC, Kep FiAនិង រដ្ឋបាលខេត្តកែប<br>- មន្ទីរទេសចរណ៍ខេត្ត | ត្រីមាសទី២ ឆ្នាំ២០២០ | 800 | H |
| ៥.៤ ស្វែងរកដៃគូដើម្បីគាំទ្រគម្រោង | ៥.៤.១ បញ្ជ្រាបផែនការសកម្មភាពទៅក្នុងផែនការថ្នាក់ជាតិ ផែនការវិនិយោគថ្នាក់ខេត្តថ្នាក់ស្រុកនិងថ្នាក់ឃុំ | ផែនការសកម្មភាពត្រូវទទួលស្គាល់និងបញ្ជ្រាបនៅគ្រប់កម្រិត | - DFC, Kep FiA/DAFF និងរដ្ឋបាលខេត្តកែប | ២០២០-២០២១ | 0 | H |
| | ៥.៤.២ រៀបចំគម្រោងនិងស្វែងរកដៃគូផ្តល់ជំនួយ | គម្រោងត្រូវបានរៀបចំតាមពេលវេលានិងតម្រូវការ | - DFC, Kep FiA/DAFF MCC និងរដ្ឋបាលខេត្តកែប | ២០២០-២០២២ | 0 | H |
| **គោលបំណងទី៦៖ ពង្រឹងយន្តការគ្រប់គ្រងចម្រុះ ដើម្បីធានាបានការគ្រប់គ្រងធនធានជលផលក្នុងតំបន់គ្រប់គ្រងជលផលខេត្តកែបប្រកបដោយប្រសិទ្ធភាពខ្ពស់** | | | | | | |
| ៦.១ បង្កើតនិងប្រត្តិបត្តិនៃគណៈកម្មការគ្រប់គ្រងថ្នាក់ខេត្តដើម្បីគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប | ៦.១.១បង្កើតគណៈកម្មការគ្រប់គ្រងថ្នាក់ខេត្ត | សេចក្តីសម្រេចរបស់ខេត្ត | - រដ្ឋបាលខេត្តកែប | ២០១៨ | | H |
| | ៦.២.១ ប្រជុំជារៀងរាល់៦ខែម្តង ដើម្បីពិនិត្យនិងសម្រេចរាល់ការងារដែលស្នើដោយ TWG-Kep MFMA | កំណត់ហេតុប្រជុំ | - រដ្ឋបាលខេត្តកែប | ២០១៩ - ២០២១ | 8,000 | H |

| | | | | | | |
|---|---|---|---|---|---|---|
| ៦.២ បង្កើតនិងប្រតិបត្តិនៃក្រុម ការងារបច្ចេកទេសស្តីពីតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប | ៦.២.១បង្កើតក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត | សេចក្តីសម្រេចរបស់ខេត្ត | - រដ្ឋបាលខេត្តកែប | ២០១៨ | | H |
| | ៦.២.២ ប្រជុំជាទៀងរាល់៣ខែម្តងដើម្បីពិនិត្យនិងពិភាក្សារាល់សកម្មភាពនៃការគ្រប់គ្រង | កំណត់ហេតុប្រជុំ | - រដ្ឋបាលខេត្តកែប | ២០១៩ - ២០២១ | 16,000 | H |
| ៦.៣ រាយការណ៍ពីលទ្ធផលនៃការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលទៅថ្នាក់ជាតិ ដើម្បីទទួលបានការគាំទ្រពីរាជរដ្ឋាភិ-បាលនិងអង្គការពាក់ព័ន្ធ | ៦.៣.១ ធ្វើបទបង្ហាញពីលទ្ធផលនៃការគ្រប់គ្រងក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិជាទៀងរាល់៦ខែម្តង | អនុសាសន៍និងការគាំទ្រ | DFC | ២០១៩ - ២០២២ | 0 | M |
| ៦.៤ រាយការណ៍ពីលទ្ធផលនៃការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលទៅថ្នាក់តំបន់និងអន្តរជាតិ ដើម្បីទទួលបានការគាំទ្រ | ៦.៤.១ រៀបចំរបាយការណ៍ពីសកម្មភាពនិងលទ្ធផលទៅ SEAFDEC ជាទៀងរាល់ត្រីមាស | របាយការណ៍ប្រចាំត្រីមាស | DFC | ២០១៩ - ២០២២ | 0 | H |
| | ៦.៤.២ រាយការណ៍ពីស្ថានភាពប្រព័ន្ធអេកូឡូស៊ីផ្កាថ្មនិងស្មៅសមុទ្រទៅអង្គការ ICRI | របាយការណ៍ប្រចាំឆ្នាំ | DFC និង MCC | ២០១៩ - ២០២២ | 0 | M |
| ៦.៥ ពង្រឹងកិច្ចសហការទ្វេភាគីរវាងខេត្តកៀងយ៉ាង និងខេត្តកែប ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង | ៦.៥.១ ពិនិត្យកិច្ចព្រមព្រៀងដែលមានស្រាប់ ហើយបើអាចបញ្ជ្រាបការងារតំបន់គ្រប់គ្រងជលផលទៅក្នុងកិច្ចព្រមព្រៀងទាំងនោះ | កិច្ចព្រមព្រៀងត្រូវបានដាក់បញ្ចូលការងារតំបន់គ្រប់គ្រងជលផលខេត្តកែប | រដ្ឋបាលខេត្តកែប | ២០១៩ - ២០២២ | 500 | M |

| | | | | | | |
|---|---|---|---|---|---|---|
| ធានធានជលផលនៃខេត្តទាំងពីរ | ៦.៥.២ បង្កើតយន្តការចែករំលែកព័ត៌មានពីការគ្រប់គ្រងធនធានជលផលរវាងខេត្តកៀងយ៉ាងនិងកែបតាមរយៈការធ្វើបទបង្ហាញក្នុងកិច្ចប្រជុំទ្វេរភាគីឬទស្សនកិច្ច | - យ៉ាងហោចណាស់កម្មវិធីប្រជុំចែករំលែកបទពិសោធន៍ចំនួន០១ដងត្រូវបានរៀបចំឡើង<br>- យ៉ាងហោចណាស់ ទស្សនកិច្ចចំនួន០១ ត្រូវបានរៀបចំឡើង | រដ្ឋបាលខេត្តកែប DFC និង FiA-Kep/DAFF | ២០២០ - ២០២២ | 6,000 | M |

ឧបសម្ព័ន្ធ ២៖ ប្រកាសស្តីពីការបង្កើតតំបន់គ្រប់គ្រងជលផលនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៩៣ ប្រក កសក

# ប្រកាស
# ស្តីពី
# ការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៧/០១៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№. 200 Preah Norodam Sangkat Tonle Basak Khan Chamkarmon B V D. Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣)២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351 / 211 352, Fax : (855) 23-217 320

- កំណត់តំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប
- គ្រប់គ្រងនិងអភិរក្សធនធានជលផល ជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ីសមុទ្រឲ្យមានប្រសិទ្ធភាព
- ធានាបាននូវការនេសាទប្រកបដោយនិរន្តរភាព ដើម្បីលើកស្ទួយជីវភាពប្រជាពលរដ្ឋ
- រួមចំណែកជំរុញវិស័យទេសចរណ៍ធម្មជាតិនិងការវិនិយោគនៅតំបន់កោះខេត្តកែប
- ពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តនៅតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប រួមមាន៖ កោះពោធិ៍ កោះស្វាយព្រៃ កោះហាលត្រី កោះមាក់ប្រាង កោះអាចម៍សេះ កោះអង្រ្កង កោះស្ងួត កោះទន្សាយ កោះស្វាយ កោះកុក កោះម្ទេស និងកោះត្បាល់ ស្ថិតនៅក្នុងដែននេសាទនៃភូមិសាស្ត្រក្រុងកែប និងស្រុកដំណាក់ចង្អើរ ខេត្តកែប ដែលមានផ្ទៃក្រឡាសរុប១១ ៣០៧ (ដប់មួយពាន់បីរយប្រាំពីរ) ហិកតា ដូចមានផែនទីនិងនិយាមកា (Datum WGS 84) ជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ១ នៃប្រកាសនេះ។

**ប្រការ៤.-**

វាក្យស័ព្ទដែលបានប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

**១-កន្លែងអភិរក្សជលផល៖** ត្រូវបានកំណត់ក្នុងភូមិសាស្ត្រជាក់លាក់សម្រាប់វារីសត្វឬរុក្ខជាតិជ្រកពួន ពងកូន រីកធំធាត់ ឬរីកលូតលាស់។ កន្លែងអភិរក្សជលផលពុំអាចអនុញ្ញាតឲ្យប្រព្រឹត្តសកម្មភាពគ្រប់ប្រភេទដែលនាំឲ្យមានផលប៉ះពាល់ដល់ធនធានជលផលបានឡើយ ក្រៅពីការស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផលស្របតាមគោល-ការណ៍ដ៏ត្រឹមត្រូវ។

**២-កន្លែងការពារធនធានជលផល៖** ត្រូវបានកំណត់នៅទីតាំងជាប់ឬក្បែរកន្លែងអភិរក្សជលផល ដែលមាន

មុខងារជាសំខាន់ជួយគាំទ្រដល់កន្លែងអភិរក្សជលផល ដើម្បីធានានិរន្តរភាពធនធានជលផល។ កន្លែងការពារអាចប្រើប្រាស់ជាកន្លែងនេសាទគ្រួសារនិងសិប្បកម្ម ព្រមទាំងសកម្មភាពផ្សេងៗទៀតដែលពុំបំផ្លាញដល់ធនធានជលផលនិងជីវចម្រុះឡើយ។

**៣-ដែនជម្រកសុវត្ថិភាពជលផល៖** ត្រូវកំណត់ក្នុងភូមិសាស្ត្រជាក់លាក់សម្រាប់ការពារប្រភេទវារីសត្វមួយឬច្រើន ក្នុងដំណាក់កាលនៃវដ្តជីវិតពិសេសរបស់វា។ ការធ្វើនេសាទឬសកម្មភាពផ្សេងៗនៅក្នុងដែនជម្រកសុវត្ថិភាពជលផលត្រូវបានហាមឃាត់ក្នុងរដូវកាលជាក់លាក់ ហើយក្រោយរដូវកាលនេះ ការនេសាទជាលក្ខណៈគ្រួសារនិងសកម្មភាពផ្សេងទៀតដែលពុំប៉ះពាល់ជាអវិជ្ជមានដល់ធនធានជលផលអាចអនុញ្ញាតបានជាធម្មតា។

**៤- កន្លែងអេកូទេសចរណ៍បាតសមុទ្រ៖** ត្រូវបានកំណត់ថាជាកន្លែងដែលមានមុខងារសំខាន់សម្រាប់បម្រើឱ្យសកម្មភាពកំសាន្តនិងការពារប្រភពធនធានជីវចម្រុះ ដើម្បីធានាបានប្រាក់ចំណូលពីវិស័យទេសចរណ៍បាតសមុទ្រនិងនិរន្តរភាពធនធានជលផល។ កន្លែងនេះត្រូវបានអនុញ្ញាតសម្រាប់ការមុជទឹកកំសាន្តមើលផ្កាថ្មនិងធនធានជលផលដទៃទៀតប្រកបដោយការទទួលខុសត្រូវ ព្រមទាំងសម្រាប់ការប្រមូលព័ត៌មានវិទ្យាសាស្ត្រនិងតាមដានបម្រែបម្រួលធនធានជលផល។ ការនេសាទគ្រប់ប្រភេទនៅក្នុងកន្លែងនេះត្រូវបានហាមឃាត់។

**ប្រការ៥.-**

ការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប ស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋបាលជលផលនិងរដ្ឋបាលខេត្តកែប ដោយមានកិច្ចសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា។ ភារកិច្ចសំខាន់ៗមានដូចខាងក្រោម៖

- បង្កើតគណៈកម្មការគ្រប់គ្រងនិងក្រុមការងារបច្ចេកទេសទទួលខុសត្រូវលើតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប
- រៀបចំនិងអនុវត្តផែនការសកម្មភាពគ្រប់គ្រង
- បោះបង្គោល ដាក់ពោង និងស្លាកសញ្ញាក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប
- ស្តារទីជម្រកជលផលសំខាន់ៗឡើងវិញ ដើម្បីបង្កើនផលស្តុកត្រីនិងវារីសត្វដទៃទៀត
- បង្កើតក្រុមល្បាតដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល និងសកម្មភាពផ្សេងៗទៀតដែលប៉ះពាល់ដល់ធនធានជលផល
- សាងសង់ស្ថាក់ការត្រួតពិនិត្យនិងស្រាវជ្រាវ ព្រមទាំងផ្តល់មធ្យោបាយត្រួតពិនិត្យ
- ផ្តល់ឱកាសឲ្យសហគមន៍មានមុខរបរបន្ថែម ដើម្បីលើកកំពស់ជីវភាពរស់នៅដល់សហគមន៍មូលដ្ឋានឱ្យប្រសើរឡើង
- សិក្សាស្រាវជ្រាវ អង្កេត តាមដានលក្ខណៈជីវសាស្ត្រនិងសេដ្ឋកិច្ចសង្គម

**ប្រការ៦.-**

តំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប ត្រូវបានបែងចែកដូចខាងក្រោម៖

១. **កន្លែងអភិរក្សជលផល៖** ត្រូវបានកំណត់ចំនួន០៣ (បី) កន្លែង (លេខកូដ១ ២ និងលេខកូដ៣) មានទីតាំងស្ថិតក្នុងដែននេសាទនៃភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប និងមានផ្ទៃក្រឡាសរុប១០៩ (មួយរយប្រាំបួន) ហិកតា។ កន្លែងនេះជាបណ្តុំផ្កាថ្មនិងថ្មប៉ប្រះទឹក ដែលសមស្របសម្រាប់វារីសត្វជាច្រើនប្រភេទរស់នៅនិងពងកូន។

២. **កន្លែងការពារជលផល:** ត្រូវបានកំណត់ចំនួន០១ (មួយ) កន្លែង (លេខកូដ៤) មានទីតាំងស្ថិតនៅក្នុងដែននេសាទនៃស្រុកដំណាក់ចង្អើរនិងក្រុងកែប ខេត្តកែប និងមានផ្ទៃក្រឡា១០ ៤១២ (មួយម៉ឺនបួនរយដប់ពីរ) ហិកតា។ កន្លែងនេះមានបណ្តុំផ្កាថ្ម ស្មៅសមុទ្រ និងជម្រកធនធានជលផលដទៃទៀតជាបង្គួរ ហើយជួយគាំទ្រដល់កន្លែងគ្រប់គ្រងជលផលផ្សេងៗទៀត។

៣. **ដែនជម្រកសុវត្ថិភាពជលផល:** ត្រូវបានកំណត់ចំនួន០១ (មួយ) កន្លែង (លេខកូដ៥) មានទីតាំងស្ថិតនៅក្នុងដែននេសាទនៃស្រុកដំណាក់ចង្អើរនិងក្រុងកែប ខេត្តកែប និងមានផ្ទៃក្រឡាសរុប៤១៧ (បួនរយដប់ប្រាំពីរ) ហិកតា សម្រាប់ការអភិរក្សក្តាមសេះ។ ហាមការនេសាទក្តាមសេះក្នុងទីតាំងនេះនៅក្នុងរដូវពងកូន ចាប់ពីថ្ងៃទី០១ ខែឧសភា រហូតដល់ថ្ងៃទី៣១ ខែកក្កដា ជារៀងរាល់ឆ្នាំ។

៤. **កន្លែងអេកូទេសចរណ៍បាតសមុទ្រ:** ត្រូវបានកំណត់ចំនួន០៤ (បួន) កន្លែង (លេខកូដ៦ ៧ ៨ និងលេខកូដ៩) ដែលមានទីតាំងស្ថិតក្នុងដែននេសាទនៃភូមិកែប ក្រុងកែប ខេត្តកែប និងមានផ្ទៃក្រឡាសរុប៣៦៩ (បីរយហុកសិបប្រាំបួន) ហិកតា។ តំបន់នេះមានមុខងារសម្រាប់បំរើឲ្យសកម្មភាពកំសាន្ត សិក្សាស្រាវជ្រាវ និងកែលម្អទីជម្រកជលផល។

ផែនទីនិងនិយាមកាបែងចែកកន្លែងនីមួយៗក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប ត្រូវបានភ្ជាប់ក្នុងឧបសម្ព័ន្ធ១និង២។

**ប្រការ៧.-**

ហាមឃាត់ដាច់ខាតការធ្វើនេសាទដោយឧបករណ៍អួនអូស ឧបករណ៍នេសាទហាមឃាត់ និងសកម្មភាពផ្សេងៗទៀតដែលបង្កផលប៉ះពាល់ដល់ធនធានជលផលនៅក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប។

**ប្រការ៨.-**

ប្រភពថវិកាសម្រាប់ការងារបង្កើតនិងគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែបមានជាអាទិ៍៖

- ថវិកាជាតិ
- ដៃគូអភិវឌ្ឍន៍នានា និងវិស័យឯកជន
- សប្បុរសជន
- ចំណូលផ្សេងៗ។

**ប្រការ៩.-**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ១១.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១២ រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល** :
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ**សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកែប កំពត ព្រះសីហនុ និងខេត្តកោះកុង
- ដូចប្រការ ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១ នៃប្រកាសលេខ ១៩៣ ចុះថ្ងៃទី ១៦ ខែមេសា ឆ្នាំ២០១៨ ស្តីពីការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប




| ID | X | Y |
|---|---|---|
| 1 | 423116 | 1156590 |
| 2 | 425465 | 1156590 |
| 3 | 427983 | 1156590 |
| 4 | 430221 | 1155250 |
| 5 | 432582 | 1153840 |
| 6 | 431881 | 1151280 |
| 7 | 431242 | 1148940 |
| 8 | 430568 | 1146470 |
| 9 | 429338 | 1145600 |
| 10 | 427830 | 1144520 |
| 11 | 422645 | 1144520 |
| 12 | 419470 | 1144520 |
| 13 | 420403 | 1147600 |
| 14 | 421340 | 1150700 |
| 15 | 422317 | 1153940 |

ឧបសម្ព័ន្ធ២ នៃប្រកាសលេខ ១៩៣ ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៨ ស្តីពីការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប

| លេខកូដ | ប្រភេទកន្លែងគ្រប់គ្រងជលផល | ទំហំ (ហាត) | ឈ្មោះភូមិ ឃុំ/សង្កាត់ ស្រុក/ក្រុង | អាប់ស៊ីស (X) | អ័រដោនេ (Y) |
|---|---|---|---|---|---|
| ១ | កន្លែងអភិរក្សជលផល | ៤៩ | ភូមិកែប សង្កាត់កែប ក្រុងកែប | ៤២៥១៥៤ | ១១៤៥៧២៤ |
| | | | | ៤២៥១៥៤ | ១១៤៥០៤៧ |
| | | | | ៤២៥៥៤៥៤ | ១១៤៥០៤៧ |
| | | | | ៤២៥៦១៦ | ១១៤៥០៤៨ |
| | | | | ៤២៥៩៨៩ | ១១៤៥០៤៧ |
| | | | | ៤២៥៩៨៩ | ១១៤៥៧២៤ |
| ២ | កន្លែងអភិរក្សជលផល | ៤៥ | ភូមិកែប សង្កាត់កែប ក្រុងកែប | ៤២៣៧៤៦ | ១១៤៦០៧៤ |
| | | | | ៤២៣៧៤៦ | ១១៤៥២៦០ |
| | | | | ៤២៤៧៩៣ | ១១៤៥២៦០ |
| | | | | ៤២៤៧៩៣ | ១១៤៦០៧៤ |
| ៣ | កន្លែងអភិរក្សជលផល | ១៥ | ភូមិកែប សង្កាត់កែប ក្រុងកែប | ៤២៥១៥៥ | ១១៤៤៧២៨ |
| | | | | ៤២៥១៥៤ | ១១៤៤៥១៩ |
| | | | | ៤២៥៩៨៩ | ១១៤៤៥១៩ |
| | | | | ៤២៥៩៨៩ | ១១៤៤៧២៨ |
| | **សរុបទំហំកន្លែងអភិរក្សជលផល** | **១០៩** | | | |
| ៤ | កន្លែងការពារជលផល | ១០ ៤១២ | ស្រុកដំណាក់ចង្អើរ និងក្រុងកែប | ៣២៣១១៦ | ១១៥៦៥៨៩ |
| | | | | ៤២៥៤៦៥ | ១១៥៦៥៨៩ |
| | | | | ៤២៧៩៨៣ | ១១៥៦៥៨៩ |
| | | | | ៤៣០២២១ | ១១៥៥២៥១ |
| | | | | ៤៣២៥៨១ | ១១៥៣៨៤០ |
| | | | | ៤៣១៨៨១ | ១១៥១២៧៦ |
| | | | | ៤៣១២២៣ | ១១៤៨៨៧០ |
| | | | | ៤៣០៥៦៨ | ១១៤៦៤៧៤ |
| | | | | ៤២៩៣៣៨ | ១១៤៥៥៩៥ |
| | | | | ៤២៧៨៣០ | ១១៤៤៥១៨ |
| | | | | ៤២២៦៣១ | ១១៤៤៥២១ |
| | | | | ៤១៩៤៧០ | ១១៤៤៥២៣ |
| | | | | ៤២០៤៩៦ | ១១៤៧៩០៤ |
| | | | | ៤២១៣៤០ | ១១៥០៦៩៦ |
| | | | | ៤២២២៨៩ | ១១៥៣៨៤៦ |
| | **សរុបទំហំកន្លែងការពារជលផល** | **១០ ៤១២** | | | |

| | | | | | |
|---|---|---|---|---|---|
| ៥ | ដែនជម្រកសុវត្ថិភាពជលផល | ៤១៧ | ស្រុកដំណាក់ចង្អើរ និងក្រុងកែប | ៤២៧០៤២ | ១១៤៨៩៣៩ |
| | | | | ៤២៧០៤២ | ១១៤៩៩៣៩ |
| | | | | ៤២៩១៤២ | ១១៤៩៩៤០ |
| | | | | ៤២៩១៤២ | ១១៤៧៩៤០ |
| | | | | ៤២៧០៤២ | ១១៤៧៩៣៩ |
| | **សរុបទំហំដែនជម្រកសុវត្ថិភាពជលផល** | **៤១៧** | | | |
| ៦ | កន្លែងអេកូទេសចរណ៍បាតសមុទ្រ | ២៨៣ | ភូមិកែប សង្កាត់កែប ក្រុងកែប | ៤២៧១០៥ | ១១៥៣៩៩៦ |
| | | | | ៤២៧២១១ | ១១៥៣៩៧៩ |
| | | | | ៤២៧២១១ | ១១៥៤៩៩០ |
| | | | | ៤២៥០១៦ | ១១៥៤៩៩០ |
| | | | | ៤២៥០១៦ | ១១៥៣៣២០ |
| | | | | ៤២៥០១៦ | ១១៥២៧៩៤ |
| | | | | ៤២៦៨៤០ | ១១៥២៧៩៤ |
| | | | | ៤២៦៧៩២ | ១១៥៣២៦៤ |
| ៧ | កន្លែងអេកូទេសចរណ៍បាតសមុទ្រ | ៦៤ | ភូមិកែប សង្កាត់កែប ក្រុងកែប | ៤២៥៦៥២ | ១១៤៨៩៣៩ |
| | | | | ៤២៦៤៤៨ | ១១៤៨៩៣៨ |
| | | | | ៤២៦៤៤៨ | ១១៤៨០៧៦ |
| | | | | ៤២៥៦៥១ | ១១៤៨០៧៦ |
| ៨ | កន្លែងអេកូទេសចរណ៍បាតសមុទ្រ | ១១ | ភូមិកែប សង្កាត់កែប ក្រុងកែប | ៤២៥១៥៤ | ១១៤៥០៤៧ |
| | | | | ៤២៥៤៥៤ | ១១៤៥០៤៧ |
| | | | | ៤២៥១៥៥ | ១១៤៤៧២៨ |
| | | | | ៤២៥៥៥៥ | ១១៤៤៧២៨ |
| ៩ | កន្លែងអេកូទេសចរណ៍បាតសមុទ្រ | ១១ | ភូមិកែប សង្កាត់កែប ក្រុងកែប | ៤២៥៦១៦ | ១១៤៥០៤៨ |
| | | | | ៤២៥៩៨៩ | ១១៤៥០៤៧ |
| | | | | ៤២៥៩៨៩ | ១១៤៤៧២៨ |
| | | | | ៤២៥៦៨៩ | ១១៤៤៧២៨ |
| | **សរុបទំហំកន្លែងអេកូទេសចរណ៍បាតសមុទ្រ** | **៣៦៩** | | | |
| | **សរុបទំហំរួម** | **១១ ៣០៧** | | | |

**ឧបសម្ព័ន្ធ៣៖ សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងនិងក្រុមការងារបច្ចេកទេសតំបន់គ្រប់គ្រងផលផល ខេត្តកែប**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកែប
លេខ៖ ០៣៥/១៨សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការគ្រប់គ្រងតំបន់គ្រប់គ្រងផលផលសមុទ្រខេត្តកែប

### អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធាន
### គណៈកម្មការគ្រប់គ្រងតំបន់គ្រប់គ្រងផលផលសមុទ្រខេត្តកែប

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៩១៦/៨៣២ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការត្រាស់បង្គាប់តែងតាំងអភិបាលនៃគណៈអភិបាលខេត្តកែប សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងសេចក្តីសម្រេចលេខ ០១០/១៧សសរ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ របស់រដ្ឋបាលខេត្តកែប ស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលខេត្តកែប និងអនុលោមភាព លេខ:០៩០ប ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ
- យោងស្មារតីអង្គប្រជុំកាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ ស្តីពីការផ្លាស់ប្តូរយោបល់ក្នុងការបង្កើតតំបន់គ្រប់គ្រង ជលផលសមុទ្រខេត្តកែប នៅសាលប្រជុំសាលាខេត្តកែប
- យោងប្រកាសលេខ ១៩៣ប្រក.កសក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ ស្តីពីការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍ និងកោះទន្សាយខេត្តកែប
- ផ្អែកតាមការចាំបាច់របស់រដ្ឋបាលខេត្តកែប

## សម្រេច

**ប្រការ១.**_

បង្កើតគណៈកម្មការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រនៅខេត្តកែប ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **កែន សត្ថា** | អភិបាលនៃគណៈអភិបាលខេត្តកែប | ប្រធាន |
| ២. | លោក | **ថ្មុំ គន្ធិ** | អភិបាលរងនៃគណៈអភិបាលខេត្តកែប | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៣. | លោក | **អ៊ុក ទិបុល** | ប្រធាននាយកដ្ឋានអភិរក្សជលផល | អនុប្រធាន |
| ៤. | លោក | **ម៉ឹង មុរិន** | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៥. | លោកឧ.ត្រី | **ម៉ុង សុខេង** | ស្នងការរងនគរបាលខេត្ត | សមាជិក |
| ៦. | លោកវ.ឯក | **សៀក អេង** | មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត | សមាជិក |
| ៧. | លោក | **ពេញ តារ៉ូ** | មេបញ្ជាការនគរបាលការពារព្រំដែនទឹកលេខវ:៤៣០ | សមាជិក |
| ៨. | លោក | **យូ ចន្ទប្រសិទ្ធ** | អនុប្រធាននាយកដ្ឋានអភិរក្សជលផល | សមាជិក |
| ៩. | លោក | **កៅ មុនីរិទ្ធ** | នាយរងអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ | សមាជិក |
| ១០. | លោក | **ទៅ សុខា** | ប្រធានមន្ទីរដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | សមាជិក |
| ១១. | លោក | **កែវ ហុង** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២. | លោក | **គង់ សាវ៉ាត** | ប្រធានមន្ទីរផែនការខេត្ត | សមាជិក |
| ១៣. | លោក | **អ៊ឹម បញ្ញារិទ្ធ** | ប្រធានមន្ទីរបរិស្ថានខេត្ត | សមាជិក |
| ១៤. | លោក | **សោម ចិន្តា** | ប្រធានមន្ទីរទេសចរណ៍ខេត្ត | សមាជិក |
| ១៥. | លោក | **ម៉ម ទូច** | ប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ១៦. | លោកស្រី | **ឌិត សុខា** | អភិបាលក្រុងកែប | សមាជិក |
| ១៧. | លោកស្រី | **គឹម ចន្ធី** | អភិបាលស្រុកដំណាក់ចង្អើរ | សមាជិក |
| ១៨. | លោក | **ឈុន ច័ន្ទច័ន់ថុន** | នាយកទីចាត់ការអន្តរវិស័យសាលាខេត្ត | សមាជិក |
| ១៩. | លោក | **គឹម សុខា** | ប្រធានការិយាល័យអភិរក្សជលផល | សមាជិក |
| ២០. | លោក | **គុជ ទិរៈ** | នាយខណ្ឌរដ្ឋបាលជលផលកែប | លេខាធិការ |

**ប្រការ២._**

គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម ៖

- សម្របសម្រួលការងារគ្រប់គ្រង ការពារប្រព័ន្ធអេកូឡូស៊ីជលផល និងធនធានជលផល និងដោះស្រាយបញ្ហាផ្សេងៗ ដើម្បីអភិរក្សធនធានជលផលឲ្យមាននិរន្តរភាព
- ពិនិត្យ និងផ្តល់យោបល់ដល់ក្រុមការងារបច្ចេកទេសក្នុងការរៀបចំគោលនយោបាយ និងផែនការសកម្មភាពគ្រប់គ្រងក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប
- ស្វែងរកការគាំទ្រពីអង្គការឬដៃគូអភិវឌ្ឍន៍ ដើម្បីដំណើរការអនុវត្តផែនការសកម្មភាពក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប
- ជំរុញ និងផ្តល់យោបល់លើការអភិរក្ស ឬការអភិវឌ្ឍក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប
- ពិនិត្យ និងសម្រេចលើសំណើផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេស
- ជំរុញ និងផ្តល់យោបល់ដល់ក្រុមការងារបច្ចេកទេសក្នុងការអនុវត្តផែនការសកម្មភាព
- ជំរុញការផ្សព្វផ្សាយពីសកម្មភាព នៃការគ្រប់គ្រងក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដល់ភាគីពាក់ព័ន្ធដើម្បីបង្កើនការចូលរួម និងគាំទ្រ
- តាមដាន ត្រួតពិនិត្យ ទប់ស្កាត់ បង្ក្រាបសកម្មភាព និងប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់នៅក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប
- គណៈកម្មការនេះ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ

- រៀបចំប្រជុំរៀងរាល់៣ខែ ឬ៦ខែម្តង ដើម្បីត្រួតពិនិត្យ និងវាយតម្លៃការរីកចម្រើន និងបញ្ហាប្រឈមនៃដំណើរការគ្រប់គ្រងក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ និងធ្វើរបាយការណ៍លទ្ធផលការងារជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងប្រធានរដ្ឋបាលជលផលដើម្បីជ្រាប និងស្នើសុំគោលការណ៍ ករណីចាំបាច់ត្រូវកោះប្រជុំជាបន្ទាន់។

**ប្រការ៣._**

គណៈកម្មការមានសិទ្ធិស្នើសុំកម្លាំងអន្តរាគមន៍ពីសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត។

**ប្រការ៤._**

គណៈកម្មការមានសិទ្ធិបង្កើត និងកែសម្រួល ក្រុមការងារបច្ចេកទេសជាជំនួយការដែលមានសមាសភាពមកពីមន្ទីរ អង្គភាព អាជ្ញាធរមូលដ្ឋាន តំណាងសហគមន៍នេសាទ អង្គការ និងដៃគូអភិវឌ្ឍន៍។

**ប្រការ៥._**

-គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រារដ្ឋបាលខេត្តកែប។

**ប្រការ៦._**

សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧._**

នាយករដ្ឋបាលសាលាខេត្ត នាយកទីចាត់ការ ប្រធានអង្គភាពចំណុះរចនាសម្ព័ន្ធសាលាខេត្ត ប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធជុំវិញខេត្ត អភិបាលក្រុង ស្រុក និងសាមីខ្លួនដូចមានក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅខេត្តកែប ថ្ងៃទី [illegible] ខែកញ្ញា ឆ្នាំ២០១៨

**អភិបាល**

កេន-សត្ថា

**កន្លែងទទួល**

-ក្រសួងមហាផ្ទៃ

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-រដ្ឋបាលជលផល

-ក្រុមប្រឹក្សាខេត្ត

"ដើម្បីជូនជ្រាប"

-ដូចប្រការ៧

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកែប
លេខ:០៣៤/១៨សសរ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល
លេខ......១២៩៨.........
ថ្ងៃទី.២៥...៩...១៨...៤:៣០
បញ្ជូន..........................

## សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតក្រុមការងារបច្ចេកទេសសម្រាប់តំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប

## អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធាន
## គណៈកម្មការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃ ទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៩១៦/៩៣២ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្ដីពីការ ត្រាស់បង្គាប់តែងតាំងអភិបាលនៃគណៈអភិបាលខេត្តកែប សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងសេចក្ដីសម្រេចលេខ ០១០/១៧សសរ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ របស់រដ្ឋបាលខេត្តកែប ស្ដីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលខេត្តកែប និងអនុលោមភាពលេខ:០៩០ប ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ
- យោងស្មារតីអង្គប្រជុំកាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ ស្ដីពីការផ្លាស់ប្ដូរយោបល់ក្នុងការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប នៅសាលប្រជុំសាលាខេត្តកែប
- យោងប្រកាសលេខ ១៩៣ ប្រក.កសក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ ស្ដីពីការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍ និងកោះទន្សាយខេត្តកែប
- យោងសេចក្ដីសម្រេចលេខ០៣៥...ចុះថ្ងៃ[illegible]ខែ[illegible]ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៨......ខែកញ្ញាឆ្នាំ២០១៨ ស្ដីពីការបង្កើតគណៈកម្មការគ្រប់គ្រងតំបន់គ្រប់គ្រប់គ្រងជលផលសមុទ្រខេត្តកែប
- ផ្អែកតាមការចាំបាច់របស់រដ្ឋបាលខេត្តកែប

## សម្រេច

**ប្រការ១.-**

បង្កើតក្រុមការងារបច្ចេកទេសសម្រាប់តំបន់គ្រប់គ្រងជលផលសមុទ្រនៅខេត្តកែប ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. | លោក **ព្រុំ គន្ធិ** | អភិបាលរងនៃគណៈអភិបាលខេត្តកែប | ប្រធាន |
| ២. | លោក **អ៊ុក វិបុល** | ប្រធាននាយកដ្ឋានអភិរក្សជលផល | អនុប្រធាន |
| ៣ | លោក **ឈុន ច័ន្ទវ៉ាន់ថុន** | នាយកទីចាត់ការអន្តរវិស័យសាលាខេត្ត | អនុប្រធាន |
| ៤. | លោក **គីខ សុផានី** | នាយរងខណ្ឌរដ្ឋបាលជលផលកែប | អនុប្រធាន |
| ៥. | លោក **គឹម សុខា** | ប្រធានការិយាល័យអភិរក្សជលផល | លេខាធិការ |
| ៦. | លោក **យូ ចន្ទប្រសិទ្ធ** | អនុប្រធាននាយកដ្ឋានអភិរក្សជលផល | សមាជិក |
| ៧. | លោក **ប៉ា គឹមអាន** | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨. | លោក **ឆាន ឆៃ** | អភិបាលរងក្រុងកែប | សមាជិក |
| ៩. | លោក **លេខ សុខុម** | អភិបាលរងស្រុកដំណាក់ចង្អើរ | សមាជិក |
| ១០. | លោក **យ៉ន ប្រុស** | អនុប្រធានមន្ទីរផែនការខេត្ត | សមាជិក |
| ១១. | លោក **សុទ្ធ ពុទ្ធិម៉ានីន** | អនុប្រធានមន្ទីរ ជនសស ខេត្ត | សមាជិក |
| ១២. | លោក **ប៊ុក ឆាំង** | អនុប្រធានមន្ទីរទេសចរណ៍ខេត្ត | សមាជិក |
| ១៣. | លោក **វ៉ា ភាព** | អនុប្រធានមន្ទីរបរិស្ថានខេត្ត | សមាជិក |
| ១៤. | លោក **ហ៊ូ ផល្លាវ៉ាទី** | អនុប្រធានមន្ទីរសាធារណៈការនិងដឹកជញ្ជូន | សមាជិក |
| ១៥. | លោកវ.ទោ **ពិន យ៉ន** | មេបញ្ជាការរងនគរបាលការពារព្រំដែនទឹកវរៈ៤៣០ | សមាជិក |
| ១៦. | លោកវ.ទោ **ភើត សារុំ** | នាយការិយាល័យគ្រប់គ្រងជនបរទេស | សមាជិក |
| ១៧. | លោក **កៅ មុនីរិទ្ធ** | នាយរងអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ | សមាជិក |
| ១៨. | លោក **ចក់ ស៊ីនាថ** | នាយផ្នែករដ្ឋបាលជលផលដំណាក់ស្ដេច | សមាជិក |
| ១៩. | លោក **ទូន ប៊ុនថេន** | ប្រធានមន្ទីរបច្ចេកទេសសន្តិសុខកងរាជអាវុធហត្ថ | សមាជិក |
| ២០. | មេឃុំ/ចៅសង្កាត់ទាំង៥ | | សមាជិក |
| ២១. | លោក Paul Ferber | នាយកអង្គការ MCC | សមាជិក |
| ២២. | លោក **លូ ទន្ធី** | អ្នកសម្របសម្រួលអង្គការ IUCN | សមាជិក |
| ២៣. | លោក **ឡេង ស៊ីវណ្ណា** | តំណាងអង្គការ SEAFDEC-UNEP/GEF | សមាជិក |
| ២៤. | លោកប្រធានគណៈកម្មការសហគមន៍នេសាទអូរក្រសារ | | សមាជិក |
| ២៤. | លោកប្រធានគណៈកម្មការសហគមន៍នេសាទកំពង់ត្រឡាច | | សមាជិក |
| ២៦. | លោកប្រធានគណៈកម្មការសហគមន៍នេសាទភូមិថ្មី | | សមាជិក |
| ២៧. | លោកប្រធានគណៈកម្មការសហគមន៍នេសាទកែប | | សមាជិក |
| ២៨. | លោកប្រធានគណៈកម្មការសហគមន៍នេសាទអង្កោល | | សមាជិក |
| ២៩. | លោកស្រីប្រធានគណៈកម្មការសហគមន៍ទេសចរណ៍កោះទន្សាយ | | សមាជិក |

**ប្រការ២.-**

ក្រុមការងារបច្ចេកទេសនេះ មានភារកិច្ចដូចខាងក្រោម ៖

- ការពារ និងអភិរក្សធនធានជលផលសមុទ្រ និងទីជម្រកក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប
- រៀបចំរបាយការណ៍បច្ចេកទេស និងផែនទីសម្រាប់បង្កើត និងដំណើរការក្នុងតំបន់គ្រប់គ្រងជលផល
- រៀបចំសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត ស្ដីពីដំណើរការគ្រប់គ្រងក្នុងតំបន់គ្រប់គ្រងជលផល

- ធ្វើបច្ចុប្បន្នភាព និងផែនការសកម្មភាពគ្រប់គ្រងក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ
- អប់រំផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ ភ្ញៀវទេសចរ និងអ្នកពាក់ព័ន្ធ ពីសកម្មភាពនៃការគ្រប់គ្រងក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ
- អនុវត្តផែនការសកម្មភាពឲ្យមានប្រសិទ្ធភាព និងតាមដានត្រួតពិនិត្យ វាយតម្លៃវឌ្ឍនភាពគម្រោង
- រៀបចំប្រជុំរៀងរាល់៣ខែម្តង ឬតាមការចាំបាច់ ដើម្បីពិនិត្យ និងពិភាក្សារាល់សកម្មភាព និងរៀបចំរបាយការណ៍ជូនគណៈកម្មការគ្រប់គ្រងក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ
- អនុវត្តសកម្មភាពផ្សេងៗទៀត ដែលគណៈកម្មការគ្រប់គ្រងក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រប្រគល់ជូន។

**ប្រការ៣.-**

ក្រុមការងារបច្ចេកទេសមានសិទ្ធិសុំអន្តរាគមន៍ និងអនុសាសន៍ពីប្រធានគណៈកម្មការគ្រប់គ្រងក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

**ប្រការ៤.-**

សមាជិកក្រុមការងារបច្ចេកទេសត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានឬតំណាងដោយមានការឯកភាពពីប្រធានគណៈកម្មការគ្រប់គ្រង។ ចំពោះស្ថាប័ន ឬអង្គការដែលមិនមែនជាសមាជិកអាចស្នើសុំចូលរួមក្នុងកិច្ចប្រជុំបាន។

**ប្រការ៥.-**

ការផ្លាស់ប្តូរ ឬសុំចូលជាសមាជិកថ្មី នៃក្រុមការងារបច្ចេកទេសត្រូវមានការឯកភាពពីប្រធានគណៈកម្មការគ្រប់គ្រងក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប ដោយមានការស្នើសុំពីប្រធានក្រុមការងារបច្ចេកទេសសម្រាប់តំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប។

**ប្រការ៦.-**

នាយករដ្ឋបាលសាលាខេត្ត នាយកទីចាត់ការ ប្រធានអង្គភាពចំណុះរចនាសម្ព័ន្ធសាលាខេត្ត ប្រធានមន្ទីរ-អង្គភាពពាក់ព័ន្ធជុំវិញខេត្ត អភិបាលក្រុង ស្រុក និងសាមីខ្លួនដូចមានក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេច ះឲ្យទទួលបានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅខេត្តកែប ថ្ងៃទី ១៤ ខែ[illegible] ឆ្នាំ២០១៨

អភិបាល

កែន.សត្ថា

**កន្លែងទទួល**

- ក្រសួងមហាផ្ទៃ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រដ្ឋបាលជលផល
- ក្រុមប្រឹក្សាខេត្ត
- គណៈកម្មការគ្រប់គ្រងក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រខេត្តកែប

"ដើម្បីជូនជ្រាប"

- ដូចប្រការ៦

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ